រៀបរៀងដោយ លោកអាចារ្យ

**ឯក ញឹម ធម្មិស្សរោ**

# ធម៌គិរីមានន្ទសូត្រ ប្រែ

## បទព្រហ្មគីតិ

សូត្រនេះគឺអានន្ទ    អនុជតន់ភក្ត្រប្រឹមប្រិយ៍
បានស្តាប់ព្រះជិនស្រី    នាំសេចក្តីមកពណ៌នា ។
ថាមានកាលមួយថ្ងៃ    ព្រះចមត្រៃភពភគវា
ព្រះអង្គគង់នៅនា    ក្រុងភារាសាវត្ថី ។
ក្នុងវត្តជេតពន    ដែលមហាជនទាំងប្រុសស្រី
ស្គាល់ថាវត្តសេដ្ឋី    ឈ្មោះអនាថបិណ្ឌិក ។
សាងថ្វាយព្រះមុនី    មានផែនទីធំពន្លឹក
ប្រគេនទានបាយទឹក    ថ្ងៃយប់ព្រឹកមិនដែលឃ្លាត ។
គ្រានោះថ្ងៃសាយណ្ហ    គិរីមានន្ទមានអាពាធ
អានន្ទចូលអភិវាទ    បង្គំបាទព្រះមានជោគ ។
ក្រាបទូលព្រះភគវា    ថាគិរីមានន្ទមានរោគ
អាពាធក្នុងខ្លួនលោក    ជាទម្ងន់ធ្ងន់ណាស់ហើយ ។
ហេតុនេះសូមព្រះអង្គ    ជួយស្រោចស្រង់ឱ្យសះស្បើយ
មានតែព្រះអង្គហើយ    ជួយសង្គ្រោះឱ្យទានផង ។
សម្តេចព្រះភគវន្ត    ប្រោសអានន្ទមិនឱ្យហ្មង
ទ្រង់ឆ្លើយតបវិញស្នង    ដូចបំណងមិនយូរឡើយ ។
ថាណ្ហើយចុះអានន្ទ    អនុជតន់ទៅបានហើយ
ជម្ងឺនឹងសះស្បើយ    ដោយសារសូត្រសញ្ញាដប់ ។
គិរីមានន្ទនោះ    លុះបានស្តាប់សញ្ញាចប់
អាពាធរោគនឹងស្ងប់    បានរម្ងាប់គ្រានោះហោង ។

សញ្ញាទីមួយថា ភិក្ខុណាអ្នកប៉ុនប៉ង
ប្រាថ្នានឹកបំណង ក្នុងសាសនាតថាគត ។
ហើយចូលទៅកាន់ព្រៃ នៅអាស្រ័យធ្វើជាវត្ត
ដោយម្លប់ឈើបពតិ ឬសំចតក្នុងផ្ទះស្ងាត់ ។
ហើយតាំងលើកខន្ធ៥ សញ្ញាចាំគ្មានវិបត្តិ
ដើម្បីនឹងកំចាត់ កងអវិជ្ជាថាដូច្នេះ ។

## ចប់ គំណាព្យទី១

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់នូវសញ្ញាទាំងឡាយ១០នេះ ប្រាប់ទៅព្រះអានន្ទ ដើម្បីឱ្យអានន្ទទៅសំដែងនូវធមិដល់ព្រះគិរីមានន្ទ ដែលលោកកំពង់តែមានរោគជាទំងន់ ។

សញ្ញាទី ១ គឺ **អនិច្ចសញ្ញា** សេចក្តីសំគាល់ថាមិនទៀង ក្នុងខន្ធ ៥ ដូច្នេះគឺៈ

## បទពាក្យ ៧

ឱអស់រូបសត្វទាំងឡាយអើយ ដែលកើតមកហើយមិនទៀងទាត់
រាល់រូបរាងកាយមិនកំណត់ តាមដោយសន្ធតិសង្ខារា ។
ទោះទាំងវេទនាក៏មិនទៀង ដឹងអ្វីតែងល្បៀងរាល់វេលា
តាមដោយអារម្មណ៍មកប៉ះពារ សុខប្រែក្លាយជាទុក្ខវិញបាន ។
រីឯសញ្ញាការចំណាំ សំគាល់មិនចាំភ្លាត់ទីស្ថាន
តែងល្បៀងមិនល្អះក្នុងសន្តាន ចួនកាលក៏ស្មានថាទៅខុស ។
ទោះបីសង្ខារការតាក់តែង ក៏ឃើញជាក់ស្តែងទាំងស្រីប្រុស
ចួនកាលតាក់តែងក្នុងផ្លូវខុស ជាហេតុឱ្យមនុស្សក្លាយជាសត្វ ។
សូម្បីវិញ្ញាណសេចក្តីដឹង មិនដែលនៅនឹងតែងវិបត្តិ
វិនាសទៅតាមធម្មតាចាត់ ចូរប្រុងប្រយ័ត្នក្នុងសង្ខារ ។

## ចប់ អនិច្ចសញ្ញា ក្នុងខន្ធ៥

សញ្ញាទី ២ គឺ **អនត្តសញ្ញា** សេចក្ដីសំគាល់ថាមិនមែនខ្លួន ក្នុងអាយតនៈទាំង១២ ដូច្នេះគឺះ

ឱភ្នែកនឹងរូបនៃគេយើង ដែលបានកើតឡើងទាំងស្រីប្រុស
មិនមានខ្លឹមសារសូន្យទាំងអស់ មិនជារបស់នៃខ្លួនឡើយ ។
រីឯត្រចៀកនឹងសំឡេង ស្រីប្រុសចាស់ក្មេងប្រាប់ឱ្យហើយ
មិនមែនខ្លួនទេណាអ្នកអើយ ចូរដឹងឱ្យហើយកុំកើតទុក្ខ ។
ច្រមុះនឹងក្លិនជាគូគ្នា អារម្មណ៍ប៉ះពារកើតវិតក្ក
មិនមែនខ្លួនឡើយមិនមានសុខ បើគិតទៅមុខទុក្ខគ្មានស្បើយ ។
រីឯអណ្ដាតគូនឹងរស មិនមែនរបស់ខ្លួនសោះឡើយ
ចូរគិតដកចិត្តទុកឱ្យហើយ កុំធ្វើតោះតើយត្រូវតែខំ ។
ឯកាយជាគូនឹងសម្ផស្ស លោកអ្នកសប្បុរសកុំច្រឡំ
ថាកាយនៃខ្លួនហើយអភិរម្យ កាយនេះប្រជុំទុក្ខឥតស្បើយ ។
សូម្បីតែចិត្តនឹងចេតសិក នោះក៏ពុំនឹកថាខ្លួនឡើយ
មិនមែនខ្លួនទេណាអ្នកអើយ ចូរដឹងឱ្យហើយក្នុងសង្ខារ ។

## ចប់ អនត្តសញ្ញាទី២ ក្នុងអាយតនទាំង១២!

សញ្ញាទី ៣ គឺ **អសុភសញ្ញា** សេចក្ដីសំគាល់ថាមិនស្អាតក្នុងកៈរជ្ជកាយដូច្នេះគឺះ

រីអស់រូបកាយសត្វក្នុងលោក សុទ្ធសឹងស្មោគគ្រោកពេកហួសខ្នាត
ផ្ទុកពេញទៅដោយគ្រឿងមិនស្អាត មិនគួរសង្វាតនឹងរូបកាយ ។
បើគិតឃើញហើយគួរកុំស្អប់ គួរគិតត្រឡប់ជានឿយណាយ
គួរកុំស្រឡាញ់រូបទាំងឡាយ ព្រោះកាយនេះដូចអង្កត់ឧស ។
ក្នុងផ្ទៃផ្ទុកពេញដោយលាមក មិនគួរដេកលក់ក្នុងការខុស
បើចិត្តមន្ទិលគួរខំដុស ខំខាត់ឱ្យអស់អវិជ្ជា ។
រូបនេះមានស្បែកស្រោបពីក្រៅ ជាទីលំនៅរោគនានា
សក់រោមក្រចកធ្មេញចម្មា មំសាសរសៃឆ្អឹងនឹងខួរ ។
ទាចបេះដូងថ្លើមវាវក្រពះ សួតពោះវៀនខ្លះធំចងព្យួរ
ពោះវៀនតូច១ឆ្ងាយដូចព្ជួរ ពេនពេញពោះគួរឱ្យនឹកល្អើម ។

អាហារថ្មីចាស់ប្រមាត់ស្លេស្ម នឹងខ្ទុះឈាមញើសហូរសើម១
ខ្លាញ់ខាប់ទឹកភ្នែកចេញគួរខ្ពើម ខ្លាញ់រាវហូរផ្ញើមតាមសន្លាក់ ។
មានទាំងទឹកមាត់ទឹកសម្បោរ ទឹករំអិលហូរហៀរប្រឡាក់
ទឹកមូត្រសឹងមានក្រពះដាក់ ទាំងអស់នេះអ្នកចូរជ្រាបដឹង ។
មិនស្អាតយ៉ាងនេះគ្រប់រូបកាយ គួរកើតនឿយណាយហើយខំប្រឹង
ខំប្រិតខំប្រៀនទឹកជញ្ជឹង រំពឹងរកផ្លូវទៅនិព្វាន ។

## ចប់ អសុភសញ្ញាទី៣ ភ្លូខភៈវង្វាយ!

សញ្ញាទី ៤ គឺ **អាទីនវសញ្ញា** សេចក្តីសំគាល់ថាកៈរជ្ជកាយ មានទុក្ខទោសច្រើនយ៉ាងដូច្នេះគឺៈ

ឱកាយនេះហើយមានទុក្ខច្រើន មានទោសចម្រើនពុំបានសុខ
រូបកាយចាស់ក្មេងជាសម្បុក សម្បូរដោយទុក្ខទោសរោគា ។
រោគកើតក្នុងភ្នែកក្នុងត្រចៀក ចេញខ្ទុះគួរស្បៀកល្អើមណាស់ណា
កើតក្នុងច្រមុះក្នុងជីវ្ហា កើតក្នុងកាយាពាសពេញខ្លួន ។
រោគកើតក្នុងក្បាលបណ្តាលទុក្ខ ត្រចៀកនឹងមុខគួរថែថួន
មានកើតក្នុងមាត់ផុតក្តីស្ងួន រោគខ្លះមានចួនកើតក្នុងធ្មេញ ។
រោគក្អករោគហឺតរោគឫសដូង ស៊ីច្រមុះខូងខូចមិនពេញ
រោគក្តៅក្រហាយកាយក្តៅស្ទេញ រោគជរាដេញសត្វទាំងហ្វូង ។
រោគឈឺក្នុងពោះរោគវិលមុខ រោគមួលរោគចុកសៀតដើមទ្រូង
រោគចុះផ្ទៃភ្នែកស្លក់ស្លាំងខូង រោគឃ្លង់មួលរូងបាទចេញឈាម ។
រោគស្រែងរោគស្រកីអណ្តែង រោគឆ្កួតជ្រូកតែងឆ្កួតគ្មានយាម
រោគកមរលាយរមាស់ឈាម រលកកែវទាមតោងខានដេក ។
អម្បៅអម្បែកក្នុងត្រចៀក ដម្បៅងារល្បៀកល្អើមពន់ពេក
រោគក្តួតចេញឈាមគួរសង្វេគ មិនគួរតម្រេកនឹងរូបកាយ ។
មានទាំងរោគឆ្កួតឡប់ប្រមាត់ រោគគ្រុនផ្អែមមាត់ប្រមេះស្វាយ
រោគឫសដូងបាទរោគផ្តួតក្លាយ ឫសដូងក្នុងកាយទ្វារប្រាំមួយ ។
អាពាធពីប្រមាត់កម្រើក ពីស្លេស្មកក្រើកញ៉ូររញ្ជួយ

រំជួលតាំងឡើងឱ្យកើតព្រួយ　　មិនកើតតែមួយមានសុសសាយ ។
អាពាធកើតពីខ្យល់កម្រើក　　ធ្វើឱ្យកក្រើករំពើកកាយ
ញាប់ញ័រសព្វសាច់មិនសប្បាយ　　ឱ្យកើតខ្វល់ខ្វាយទាំងថ្ងៃយប់ ។
អាពាធកើតពីធាតុទាំងបួន　　កម្រើកក្នុងខ្លួនមិនមានឈប់
ឱ្យកើតឈឺចាប់ទាំងថ្ងៃយប់　　កាយនេះឧបទ្រពដោយរោគា ។
អាពាធកើតពីប្រែរដូវ　　ត្រជាក់ជាក្តៅរោគពាធា
បៀតបៀនឱ្យបានទុក្ខវេទនា　　ពួកជនគ្រប់គ្នាចៀសពុំបាន ។
អាពាធកើតពីឥរិយាបថ　　ប្រើមិនប្រាកដហួសប្រមាណ
ដេកពេកដើរពេកក៏កើតមាន　　ឈឺថ្កាត់ក្នុងប្រាណបានវេទនា ។
ចូនកាលបរិភោគបាយចំណី　　មិនតាមប្រក្រតីខុសវេលា
បង្កើតទៅជាព្យាធិរោគា　　លោកអ្នកគ្រប់គ្នាចូរប្រិតប្រៀន ។
អាពាធកើតពីសឹកសត្រូវ　　ដែលដើរដោយផ្លូវមកបៀតបៀន
កើតពីព្យាយាមខំសូត្ររៀន　　ដែលខ្លួនខ្មាសអៀនក្តីល្ងង់ខ្លៅ ។
អាពាធកើតពីផលអកុសល　　ដែលខ្លួនមិនស្គាល់ការខុសត្រូវ
ចេះតែធ្វើបាបបំពានទៅ　　កម្មនេះស្ថិតនៅមានក្នុងលោក ។
សូម្បីត្រជាក់រងារក្តៅ　　ឃ្លានស្រេកក៏ហៅថាកើតរោគ
ទោះឈឺជុះនោមការស្នោកគ្រោក　　ក៏ហៅថារោគទាំងអស់ហើយ ។
ហេតុនេះរូបកាយយើងគេក្តី　　គ្រប់រូបប្រុសស្រីកុំកន្តើយ
ខំគិតរកផ្លូវធម៌ឱ្យហើយ　　ចូរកុំប្រងើយក្នុងសង្ខារ ។

## ចប់ អាទីនវសញ្ញាទី៤ ភ្លួខភរជ្ជភាយ!

សញ្ញាទី ៥ គឺ **បហានសញ្ញា** សេចក្តីសំគាល់ក្នុងកិរិយាលះបង់នូវវិតក្កៈ ៣ យ៉ាងនឹងអកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយខំលះបង់ឱ្យវិនាសចេញចាកចិត្តអស់ទៅដូច្នេះគឺ:

លោកអ្នកទាំងឡាយត្រូវលះបង់　　នូវធម៌ជាអង្គទោស៣យ៉ាង
ដែលធ្វើចិត្តសត្វគ្រប់រូបរាង　　តែងឱ្យអ្នកនាងកើតទុក្ខា ។
ព្រោះធម៌ជាទោសមន្ទិលចិត្ត　　ធ្វើឱ្យវិប្បរិតខុសធម្មតា

តែងមានក្តីល្មោភដោយតណ្ហា ឱ្យកើតប្រាថ្នាការផ្សេងៗ ។
ទីមួយគឺកាមវិតក្កៈ ធ្វើចិត្តលោកអ្នកទាំងចាស់ក្មេង
ត្រិះរិះរកកាមដើម្បីលេង គគ្រឹងគគ្រេងល្បែងហឺហា ។
ទីពីរព្យាបាទវិតក្កៈ ធ្វើចិត្តនាងអ្នកឱ្យក្តៅផ្សា
បើខឹងកើតឡើងវេលាណា ផ្ទំខឹងទុកថាមិនអ្វីទេ ។
ទីបីវិហិង្សាវិតក្កៈ ត្រិះរិះរកថ្នាក់បៀតបៀនគេ
ឱ្យបានទុក្ខទោសគ្មានទំនេរ យប់ថ្ងៃគិតរេរកតែរឿង ។
ភវង្គៈចិត្តដូចទឹកថ្លា ធម៌បីឧបមាដូចពណ៌លឿង
លាយក្នុងទឹកច្រើនគង់ព្រឿងៗ ព្រោះជាតិថ្នាំលឿងលាយក្នុងទឹក ។
ចិត្តសត្វដែលកើតអកុសល ធ្វើបាបមិនស្គាល់យប់ថ្ងៃព្រឹក
ព្រោះទោសទាំងនេះធំពន្លឹក ចូលមកឱ្យនឹកខាងអកុសល ។
ហេតុនេះលោកអ្នកត្រូវបង្ខំ លះចិត្តដែលនាំឱ្យកង្វល់
ឱ្យអស់គ្រប់យ៉ាងកុំឱ្យសល់ កុំមានកង្វល់ក្នុងសង្ខារ ។

## ចប់ បហានសញ្ញាទី៥ ក្នុងវិតក្កធម៌៣យ៉ាង!

សញ្ញាទី ៦ គឺ **វិរាគសញ្ញា** សេចក្តីសំគាល់ក្នុងកិរិយាប្រាស់ចាកតម្រេក ព្រោះពិចារណា ឃើញគុណរបស់ព្រះនិព្វានជាទីរម្ងាប់នូវសង្ខារទាំងឡាយដូច្នេះគឺៈ

រីព្រះនិព្វានជាធម៌ល្អិត ជាធម៌ប្រណិតឧត្តមពេក
ជាទីរម្ងាប់នូវតម្រេក ដែលសត្វតែងស្រេកដោយតណ្ហា ។
ជាទីរម្ងាប់នូវកំណើត ដែលកើតជាសត្វសង្ខារា
ជាបុណ្យជាបាបដរាណា ឱ្យត្រាតែអស់គ្មានសល់ឡើយ ។
លះឧបធិទាំងពួងបាន តណ្ហាប៉ុន្មានក៏សូន្យហើយ
រំលត់អស់ទុក្ខសុខឥតស្បើយ ធម៌យ៉ាងនេះហើយហៅនិព្វាន ។

## ចប់ វិរាគសញ្ញាទី៦ ក្នុងសង្ខារទាំងពួង!

សញ្ញាទី៧គឺ **និរោធសញ្ញា** សេចក្ដីសំគាល់ក្នុងកិរិយារំលត់នូវសេចក្ដីទុក្ខទាំងពួង ព្រោះពិចារណា ឃើញគុណរបស់ព្រះនិព្វានជាទីរំលត់នូវសង្ខារទាំងឡាយដូច្នេះគឺៈ

វីព្រះនិព្វានជាធម៌ល្អិត ជាធម៌ប្រណិតឧត្ដមពេក
ជាទីរម្ងាប់នូវតម្រេក ដែលសត្វតែងស្រេកដោយតណ្ហា ។
ជាទីរម្ងាប់នូវកំណើត ដែលកើតជាសត្វសង្ខារា
ជាបុណ្យជាបាបដរាណា ឱ្យត្រាតែអស់គ្មានសល់ឡើយ ។
លះឧបធិទាំងពួងបាន តណ្ហាប៉ុន្មានក៏សូន្យហើយ
រំលត់អស់ទុក្ខសុខឥតស្បើយ ធម៌យ៉ាងនេះហើយហៅនិព្វាន ។

## ចប់ និរោធសញ្ញាទី៧ ត្នូងសង្ខារនាំងពួង!

សញ្ញាទី ៨ គឺ **សព្វលោកេ អនភិរតសញ្ញា** សេចក្ដីសំគាល់ក្នុងកិរិយាអផ្សុក មិនមានសេចក្ដីត្រេកអរក្នុងលោកទាំងពួង ព្រោះពិចារណាឃើញទោសក្នុងឧបាទានទាំងឡាយ ដែលមានតណ្ហានឹងទិដ្ឋិជាបច្ច័យឱ្យកើតឡើងដូច្នេះគឺៈ

វីឧបាទានមានតណ្ហា នឹងទិដ្ឋិជាបច្ច័យកើត
ឱ្យសត្វប្រាថ្នាយកកំណើត វិលស្លាប់វិលកើតក្នុងត្រៃភព ។
ដោយហេតុពួកសត្វភាន់គំនិត មិនបានរិះគិតឱ្យឃើញគ្រប់
មិនឃើញសត្វកើតស្លាប់គ្មានឈប់ ព្រោះមោហៈខ្ទប់បញ្ញាញាណ ។
មិនឱ្យចិត្តសត្វយល់ឃើញត្រូវ យល់ត្រង់តាមផ្លូវទៅនិព្វាន
ត្រឡប់កើតកាមុបាទាន ព្រោះទិដ្ឋិមានពីរប្រការ ។
ទីមួយប្រកាន់ថាកាយទៀង សត្វលោកតែងល្បៀងក្នុងសង្សារ
ទីពីរឃើញថាសូន្យសង្ខារ បុណ្យបាបជាការឥតអំពើ ។
ទិដ្ឋិពីរនេះដូចរាជសីហ៍ ទាំងគូរញីឈ្មោលកាចឥតស្មើ
នៅគូហារវាតែងធ្វើ ឱ្យសត្វសារពើភ័យតក់ស្លុត ។
វីកាមៈរាគាជានុស្ស័យ ទិដ្ឋិអាស្រ័យឱ្យរន្ធត់
ត្រូវមានចិត្តខ្លាចហើយខំរត់ គេចចេញឱ្យផុតពីត្រៃភព ។
ទុក្ខភ័យអាស្រ័យនឹងតណ្ហា ឱ្យសត្វនានាបានឧបទ្រព

កើតចាស់ឈឺស្លាប់គ្មានពេលឈប់ សត្វក្នុងត្រៃភពត្រូវលះបង់ ។
លះបាបដោយកាយនឹងវាចា ចិត្តទៀតសោតណាឱ្យទៀងត្រង់
កុំកាន់យកធម៌ដែលជាអង្គ ឧបាទានបង់ចងចិត្តឡើយ ។

## ចប់ សព្វលោកេ អនភិរតសញ្ញាទី៨ ក្នុងឧបាទាន!

សញ្ញាទី ៩ គឺ **សព្វសង្ខារេសុ អនភិរតសញ្ញា** សេចក្តីសំគាល់ថាមិនទៀង ក្នុងសង្ខារទាំងឡាយទាំងពួងដូច្នេះគឺៈ

គ្រហស្ថបព្វជិតគិតឡើយណាយ ខ្មាសខ្ពើមចំហាយសង្ខារា
ដែលតាក់តែងសត្វក្នុងលោកា ដោយឃើញច្បាស់ថាគួរឡើយណាយ ។
គួរខិតទ្រាំគួរស្អប់ខ្ពើម គួរកុំរអើមកុំរីករាយ
ចំពោះសង្ខារផងទាំងឡាយ ងាកចិត្តឱ្យឆ្ងាយកុំសង្ការ ។
បើឃើញយ៉ាងនេះគួរខ្មាសទុក្ខ ខ្មាសទោសទៅមុខកុំស្នេហា
គួរខ្ពើមគួររអើមពេកណាស់ណា ក្នុងសង្ខារាផងទាំងឡាយ ។
ហេតុនេះលោកអ្នកទាំងអស់គ្នា គួរប្រឹងភាវនារាល់រូបកាយ
គួរលះចោលខន្ធកុំសោកស្តាយ កុំចង់សប្បាយហួសខ្នាតពេក ។

## ចប់ សព្វសង្ខារេសុ អនភិរតសញ្ញា ក្នុងសង្ខារទាំងឡាយទាំងពួង!

សញ្ញាទី ១០ គឺ **អានាបានស្សតិ** សេចក្តីសំគាល់ក្នុងកិរិយារឭកតាមនូវខ្យល់ដង្ហើមចេញចូល ហើយតំកល់នូវស្មារតី មានមុខបែរឆ្ពោះទៅកាន់ព្រះកម្មដ្ឋានដូច្នេះគឺៈ

សញ្ញាទីដប់ភិក្ខុណា បួសក្នុងសាសនាព្រះជិនស្រី
បួសហើយបានចូលទៅកាន់ព្រៃ ជ្រកនៅអាស្រ័យដោយគល់ឈើ ។
ឬនៅក្នុងកុដិក្នុងផ្ទះស្ងាត់ អង្គុយប្រតិបត្តិដោយអើពើ
តាំងពែនជើងស្តាំដាក់ខាងលើ កាយទៀតក៏ធ្វើឱ្យត្រង់ខ្លួន ។
ហើយតាំងដំកល់នូវស្មារតី បិទទ្វារទាំងបីឱ្យស្ងប់ស្ងួន
ហើយមានសតិនឹងមាំមួន តាំងរាប់ចំនួនខ្យល់ចេញចូល ។

ខ្យល់ដកដង្ហើមចេញចូលវែង ដឹងក្នុងខ្លួនឯងសព្វទាំងមូល
បើដកដង្ហើមខ្លីចេញចូល ក៏ដឹងត្រកូលខ្យល់ទាំងអស់ ។
ភិក្ខុសិក្សាដឹងពួកខ្យល់ ចេញចូលឥតសល់ដោយច្បាស់លាស់
រម្ងាប់នូវខ្យល់គ្រោតគ្រាតអស់ ដែលជារបស់សង្ខារា ។
ភិក្ខុសិក្សាដើម្បីសោយ នូវបីតិដោយចិត្តជ្រះថ្លា
ព្រមទាំងសុខកាយស្រួលចិន្តា ដែលកើតពីកាយវិវេក ។
ភិក្ខុសិក្សាដើម្បីដឹង ចិត្តសង្ខារប្រឹងលះតម្រេក
រម្ងាប់នាមកាយគ្រោតគ្រាតពេក ដោយចិត្តវិវេកក្នុងសង្ខារ ។
ញុំាងចិត្តឱ្យត្រេកក្នុងអារម្មណ៍ ដែលខ្លួនសម្ងំមានវិចារ
កម្មដ្ឋានដើម្បីដោះសង្ខារ ដំកល់ក្នុងការមិនប្រមាទ ។
ប្រោនចិត្តចេញចាកនីវរណៈ មានកាមឆន្ទៈជាដើមអាទិ៍
ប្រារព្ធព្យាយាមខំសង្វាត លះបង់ប្រមាទក្នុងសង្ខារ ។
នឹកដល់អស់ខន្ធទាំងប៉ុន្មាន ដែលខ្លួនតែងបានក្នុងសង្សារ
ឱ្យកើតត្រៃលក្ខណ៍បីប្រការ មានការមិនទៀងជាប្រធាន ។
ក៏កើតវិរាគលះកិលេស រិះរកវិសេសក្នុងនិព្វាន
រំលត់កិលេសចាកសន្តាន ចាកទុក្ខទោសបានដល់និរោធ ។
រំពឹងដឹងសព្វដល់អរិយមគ្គ បញ្ញាឃើញជាក់លះលែងឆោត
ចំណែកខាងចិត្តលោកនោះសោត ក៏បាននិរោធរំលត់ហើយ ។

## ចប់ អានាបានស្សតិ ភ្នំខព្វតខ្យល់អស្សាសៈបស្សាសៈ!

សេចក្ដីរួបរួមសញ្ញា ១០ ដែលព្រះដ៏មានព្រះភាគទ្រង់ប្រទានឱ្យអានន្ទរៀន ហើយយកទៅសំដែងឱ្យគីរីមានន្ទភិក្ខុស្ដាប់ ដរាបដល់បានជាសះស្បើយរោគាពាធនោះថា ដូច្នេះគឺៈ

ហៃបានន្ទថាបើអ្នក ទៅដល់សំណាក់គីរីមានន្ទ
ចូរតាំងមេត្តាចិត្តឱ្យទន់ ហើយតាំងសូត្រមន្តគឺសញ្ញា ។
តាំងពីទី ១ ដល់ទី ១០ ដរាបដល់ចប់ទៅកាលណា
គីរីមានន្ទស្ដាប់សញ្ញា លុះចប់ក៏ជាគ្រានោះឯង ។

លំដាប់នោះក៏ព្រះអានន្ទ នាំសញ្ញាមន្តទៅសំដែង
ជំនួសព្រះអង្គដោយខ្លួនឯង ដល់ហើយក៏ថ្លែងសញ្ញាដប់ ។
គ្រានោះភិក្ខុគិរីមានន្ទ កំពុងឈឺស្ទើរសន្លប់
កាលបើបានស្តាប់សញ្ញាចប់ រោគក៏រម្ងាប់ជាទៅហោង ។

*ពាក្យកាព្យថ្លែងសេចក្តីពី គិរីមានន្ទសូត្រ*
ចប់ ដោយសង្ខេបប៉ុណ្ណេះ!

---

## សុខុមលក្ខណៈ អនិច្ចាទី ១

## បទពាក្យ ៧

ខន្ធ៥មិនទៀងតែងល្បៀងឃ្លាត លោកធាតុទាំងអស់ឥតសល់អ្វី
កើតស្លាប់ៗកើតកំណើតថ្មី ឥតបីស្រាកស្រាន្តគ្រប់ប្រាណសត្វ ។
ជរាគ្រាំគ្រាជាធម្មតា ខន្ធ៥ក្តីណាក៏វិបត្តិ
ឃ្លាតចាកក្តីពិតឫទ្ធិស្ងប់ស្ងាត់ ឥតអ្វីបញ្ឆតឱ្យទៀងបាន ។
រូបក្ខន្ធមិនទៀងគ្រប់ៗថ្នាក់ ធ្មេញបាក់សក់ស្កូវឥតសល់ខាន
ភ្នែកប្រែប្រែរជាស្គាល់មិនបាន ទីស្ថានប៉ុន្មានវង្វេងវល់ ។
ត្រចៀកច្រមុះអណ្តាតកាយ ប្រែក្លាយទាំងអស់ឥតមានសល់
សំឡេងក្លិនរសសម្ផស្សផល វិលវល់យល់ដឹងដំណឹងសព្វ ។
ធម៌ណាមិនទៀងតែងឃ្លៀងឃ្លាត ធ្វើឱ្យលោកធាតុប្រែត្រឡប់
ធម៌នេះជាទុក្ខមុខគួរស្អប់ មិនមានពេលចប់ចុះសោះឡើយ ។

## ចប់អនិច្ចាទី ១

## ទុក្ខទី ២

រូបកាយទាំងឡាយនៃពួកសត្វ វិបត្តិមិនសុខទេអ្នកអើយ
ទាំងចិត្តចេតសិកក៏ឥតស្បើយ ខន្ធ៥នោះហើយក៏ដូចគ្នា ។
ទុក្ខខ្លះប្រព្រឹត្តទៅតាមកាយ ខ្លះផ្សាយទៅតាមមនោទ្វារ

ទទួលយកទុក្ខទៅទំពារ　　វេទនាក៏សោយតាមអារម្មណ៍ ។
សញ្ញាសង្ខារនិងវិញ្ញាណ　　ទទួលសោយបានដោយនិយម
ក្រេបយកក្ដីទុក្ខក្ដៅអួលឆំ　　ទាំងតូចទាំងធំមិនសល់ខាន ។
ទុក្ខនេះឈ្មោះដើមមានដប់កង　　សត្វផងកន្លងឆ្លងមិនបាន
លោកបីជាមុំដូចជើងក្រាន　　ទ្រទុក្ខឥតក្សាន្តខានពេលណា ។
ធម៌ដែលធ្វើសត្វឱ្យកើតទុក្ខ　　ឥតសុខសប្បាយកាយចិន្ដា
ធម៌នោះជាឈ្មោះអនត្តា　　សាស្ដាទេសនាថាត្រៃលក្ខណ៍ ។

**ចប់ទុក្ខទី ២**

## ទី ៣ អនត្តា

អនត្តាប្រែថាមិនមែនខ្លួន　　សោះសូន្យមិនមួនគ្រប់៧ថ្នាក់
រូបកាយទាំងមូលជាអប្បលក្ខណ៍　　គ្រប់រូបនាងអ្នកទាំងប្រុសស្រី ។
មិនមែនរបស់យើងទេណា　　កាយចិត្តវាចាទ្វារទាំងបី
លោកនេះឬលោកខាងមុខក្ដី　　បុរីរម្យរដ្ឋខណ្ឌសីមា ។
ទោះបីបង្គាប់ប្រាប់ពន្យល់　　ក៏ឥតបានផលដូចប្រាថ្នា
ដូច្នេះនេះឈ្មោះអនត្តា　　ប្រែជាមិនមែនខ្លួនសោះឡើយ ។

## ចប់ អនត្តាទី៣ នៃ សូត្រមលក្ខណៈតែប៉ុណ្ណោះ!

## ទំនួញនាងសិរិមហាមាយា

### បទពាក្យ ៧

ឱប្រុសពន្លកមាសម្ដាយអើយ　　កូនអើយអ្នកស្គមអ្វីម្លេះណា
ម្ដាយស្ដាយអ្នកពេកឥតឧបមា　　ឧបមេយ្យយ៉ាងណាក៏ពុំបាន ។
កូនអើយកូនកើត៧ថ្ងៃ　　ខ្លួនម្ដាយក្សិណក្ស័យចាកចោលឋាន
ទៅកើតត្រៃត្រឹងសួគ៌ពិមាន　　នាឋានទេវលោកលុះឥឡូវ ។
ម្ដាយដឹងដំណឹងដោយទេវតា　　ប្រាប់ថារូបកូនល្អពេកក្រូវ
ទ្រង់ទ្រាយឆោមឆាយឥតអាស្រូវ　　ឥឡូវម្ដេចស្គមអីដល់ម្លេះ ។

ម្ដាយមើលទៅអ្នកសព្វរាងកាយ　　កូនអើយម្ដាយស្ដាយស្មើររលេះ
រលួយចិត្តថ្លើមក្នុងទីនេះ　　បើម្លេះទៅហើយយ៉ាងណាទៅ ។
ឱប្រុសម្ដាយអើយម្ដេចអភ័ព្វ　　ពីដើមអ្នកធ្លាប់មានលំនៅ
មានស្រីជំទង់ចាំគាល់ហៅ　　គ្មាននៅទំនេរយប់ថ្ងៃណា ។
មិនសមបើកូនមកក្សិណក្ស័យ　　ក្នុងព្រៃម្នាក់ឯងណាប្រុសណា
គួរណាស់តែក្ស័យក្នុងប្រាង្គប្រា　　សាទព្រះបិតាណាកូនអើយ ។
ស្គមអើយស្គមណាស់ឃើញតែឆ្អឹង　　ភ្នែកស្លក់ល្អក់ស្លឹងអស់ទៅហើយ
អ្នកឃើញម្ដាយទេប្រុសម្ដាយអើយ　　កូនអើយម្ដេចឡើយមិនចរចា ។
ម្ដាយមកជួបមុខកូនពិសី　　ហេតុអ្វីមិនស្ដីនឹងមាតា
កូនអើយក្រោកឡើងណាប្រុសណា　　កុំនៅនិទ្រាណាប្រុសអើយ ។（ស្រីសូត្រ）
នាកាលសម្ដេចព្រះសាស្ដា　　ឮព្រះវាចាមាតាហើយ　（ប្រុសសូត្រ）
ស្ដេចប្រែព្រះអង្គពុំលង់ឡើយ　　ទ្រង់ឆ្លើយតបទៅដូច្នេះថា ។
បពិត្រព្រះមេរ៍មានគុណធ្ងន់　　លើសលន់ឥតបីនឹងឧបមា
ទូលបង្គំសូមឃាត់ព្រះមាតា　　កុំសោយសោកាណាម្ចាស់អើយ ។
ទូលបង្គំមិនស្លាប់ទេម្ចាស់ថ្លៃ　　ថ្វីបើរាំរៃយ៉ាងនេះហើយ
ហេតុនេះសូមអ្នកស្រាកទុក្ខស្បើយ　　ម្ចាស់អើយសូមវិលទៅទេវលោក ។
និទានប្រវត្តិព្រះសាស្ដា　　ទុក្ករកិរិយាច្រើនប្រយោគ
រឿងមហាមាយាទ្រង់សោយសោក　　អមោក្ខដល់បុត្រវ័ត្ថពិសី ។
រឿងនេះអ្នកតែងបានស្រង់យក　　ចេញមកអំពីព្រះបាលី
ព្រមទាំងសំស្រ្កឹតសព្វសេចក្ដី　　សប្បុរសប្រុសស្រីស្ដាប់ឱ្យបាន ។
បញ្ចប់សេចក្ដីខ្លីប៉ុណ្ណេះ　　ឈប់ស្លេះបង្អង់រឿងនិទាន
សប្បុរសអ្នកស្ដាប់ទាំងប៉ុន្មាន　　សូមបានអានិសង្សច្រើនណាស់ហោង ។

## ចប់ ទំនួញនាងសិរិមហាមាយា

# ព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា

## បទពាក្យ ៧

ដំណាលកាលអង្គព្រះនាយកៈ     ស្ដេចធ្វើទុក្ករៈក្នុងព្រឹក្សា
ក្នុងព្រៃឧរុវេលស្រុកគយា     នេរញ្ជរាមហានទី ។
ជាស្ទឹងជាន់ចាស់ពីបុរាណ     ដែលបានល្បីឈ្មោះសុសធរណី
ពេលនោះសម្ដេចព្រះមុនី     ស្វែងរកពិធីពោធិញាណ ។
ទ្រង់ចូលទៅរៀនក្នុងសំណាក់     តាបសពីរនាក់ដែលបានឈាន
ទ្រង់ឃើញថារកសារៈគ្មាន     ទ្រង់ឈប់សមាទាននឹងគ្រូនោះ ។
ហើយទើបទ្រង់តាំងបធានធំ     ដោយទ្រង់និយមមិនរើរុះ
ទ្រង់តាំងព្យាយាមក្នុងទីនោះ     មិនបាច់ពិគ្រោះអ្នកដទៃ ។
ដំបូងទ្រង់ប្រើខ្យល់ចេញចូល     ឱ្យមូលប្រមូលទៅតាមផ្ទៃ
លុះខ្យល់នោះជ្រួលរំជួលក្រៃ     ក្សត្រថ្លៃស្ទើរក្ស័យព្រះជន្មា ។
ទើបទ្រង់បង្វែរអស្សាសៈ     ព្រមទាំងបស្សាសៈវាតា
ឱ្យបក់ទៅតាមព្រះសិរសា     ដោយទ្រង់ប្រាថ្នាឆាប់បានត្រាស់ ។
ខ្យល់ដែលទ្រង់ប្រើខុសទំនង     ដំណើរដើមទងប្រែក្រឡាស់
ព្រោះខុសដំណើរទំនងចាស់     ខ្យល់ប្រាសទទឹងរឹងកាយា ។
ទ្រង់បានជាប្រើខ្យល់ដូច្នេះ     ដោយទ្រង់គិតរិះជ្រួសតម្រា
ព្រោះចង់បានត្រាស់ឆាប់ណាស់ណា     ជាព្រះសាស្ដាដ៏ក្សេមក្សាន្ត ។
ក្រោយនោះទ្រង់គិតថាអាត្មា     ឆាន់ភោជនីភត្តាលើសប្រមាណ
មានធម៌ប្រមាទក្នុងសន្ដាន     ទើបបានអាត្មាក្របានត្រាស់ ។
ក៏ទ្រង់បន្ថយនូវភោជន     ដោយហេតុទ្រង់គន់គិតជ្រាបច្បាស់
ថាហេតុអាហារប្រាកដណាស់     បានជាក្រត្រាស់សម្ពោធិ ។
ព្រះលោកនាថទ្រង់ឈ្វេងយល់     វិលវល់ព្រះទ័យគៃវក់វី
តិចចុះដូច្នោះសព្វនាទី     សម្ដីបន្ថយដរាបអស់ ។
លុះអត់អាហារលែងសោយហើយ     លោកអើយពេលនោះព្រះទ្រង់យស
ស្គាំងស្គមស្លេកស្លាំងអង្គទាំងអស់     ទ្រង់យសដួលចុះលើផែនដី ។
រូបទ្រង់ដែលដួលលើពសុធា     ឥតញ្ញាតិនានាប្រុសឬស្រី

ណាមួយមកជួយថ្នាក់ថ្នមបី អង្គព្រះជិនស្រីគ្រានោះឡើយ ។
ទេវតាជាពួកស្តេចមារា ដឹងថាទ្រង់ដួលដូច្នោះហើយ
មកពោលចំអកឱ្យព្រងើយ ថាសិទ្ធត្ថអើយអ្នកត្រាស់ចុះ ។
ហើយហោះទៅទូលព្រះបិតា សុទ្ធោទនីរាជាក្នុងគ្រានោះ
ស្តេចបានជ្រាបហេតុហើយដូច្នោះ តែជ្រាបហេតុនោះថាមិនពិត ។
ចំណែកសិរិមហាមាយា គង់នៅប្រាង្គប្រាសាទវិចិត្រ
នាងជាមាតាព្រះទ្រង់ឫទ្ធិ ទ្រង់ស្ថិតនៅស្ថានត្រៃត្រឹង្សា ។
នាងដឹងថាព្រះឱរសថ្លៃ ដួលដេកក្នុងព្រៃឧរុវេលា
ម្នាក់ឯងកណ្តែងឥតគ្នីគ្នា វេទនាលំបាកឥតស្រាកឡើយ ។
នាងហោះចុះចាកត្រៃត្រឹង្សា នេត្រានាងទតយល់ច្បាស់ហើយ
ឱបបាទចមមកុដបុត្រត្រាណត្រើយ ហើយទ្រង់វិយោគសោកទួញថា ។

## ចប់ ព្រះអង្គទ្រង់ធ្វើទុក្ករកិរិយា

## បរិនិព្វានកថា

### បទពាក្យ ៧

ដំណាលកាលអង្គព្រះទ្រង់ញាណ យាងចូលនិព្វានមានកម្រឹត
ក្រោមដើមរាំងភ្នំព្រៃជុំជិត បរិស័ទមូលមិត្តពេញត្រៀបត្រា ។
នៅថ្ងៃអង្គារ ១៥ កើត ក្នុងខ្ទើតវិសាខមាសា
ឆ្នាំម្សាញ់បញ្ចស័កសំវច្ឆរា វេលាព្រឹកព្រាងខាងដើមថ្ងៃ ។
ពេលពេកបច្ចូសព្រឹកព្រហាម នាយាមអង្គារប្រសើរថ្លៃ
ពេលនោះបរិស័ទយំសោកក្រៃ ស្តាយព្រះចមត្រៃគ្រប់ៗគ្នា ។
ខ្លះស្តាយធ្លាប់ស្តាប់ច្បាប់ឱវាទ ស្តាយត្រាច់បិណ្ឌបាតតាមសាស្តា
ខ្លះស្តាយធ្លាប់ស្តាប់ស័ព្ទទេសនា គ្រប់គ្នាទាំងអស់ឥតមានសល់ ។
ក្នុងព្រៃសាលវ័នលាន់រំពង គឹកកងទាំងអស់សព្វសាកល
ផ្ការាំងជម្រុះជ្រុះទាំងផល ថ្វាយដល់ព្រះមុនិន្ទពិនលោកា ។

លុះដល់គ្រាក្រោយព្រះអានន្ទ និមន្តបិណ្ឌបាតប្លែកធម្មតា
អ្នកស្រុកស្រីប្រុសទាំងអស់គ្នា វន្ទាបង្គំយំសួរសព្វ ។
បពិត្រអានន្ទជាម្ចាស់ថ្លៃ ចុះព្រះចមត្រៃត្រៃមកុដត្រៃភព
មានព្រះគុណច្រើនយ៉ាងលើសលុប ស្តេចទ្រង់ប្រាវព្វត្រាច់ទៅណា ។
យើងខ្ញុំធ្លាប់ឃើញព្រះអរហន្ត ជាមួយអានន្ទជាធម្មតា
ថ្ងៃនេះបាត់អង្គព្រះសាស្តា មិនឃើញយាត្រានិមន្តមក ។
អានន្ទលោកមានព្រះទ័យទន់ ដោយព្វមហាជនគេសួររក
ពីរឿងព្រះអង្គមិនឃើញមក លោកយកព្រះហស្តខ្ទប់ភត្រា ។
ព្រោះអីសម្តេចព្រះទ្រង់ញាណ យាងចូលនិព្វានទៅហើយណា
បានជាបាត់បង់អង្គព្រះសាស្តា ឃើញតែអាត្មាម្នាក់ឯងនៅ ។
ញោមអើយកម្មកាចរបស់យើង ឱ្យយើងព្រាត់ប្រាស់ព្រះចមចៅ
ចាប់ដើមពីថ្ងៃនេះតទៅ យើងនៅកំព្រាគ្រប់រូបា ។
សង្ខេបសេចក្តីនៃនិទាន បរិនិព្វាននៃកថា
បញ្ចប់ប៉ុណ្ណេះស្លេះចរចា បរិបុណ្ណាបរិបូណ៌ហោង ។

## ចប់បរិនិព្វានកថា!

## និព្វានសូត្រ
## បទពាក្យ ៧

កាលអង្គសម្តេចព្រះទ្រង់ញាណ ស្តេចចូលនិព្វានមានអស្ចារ្យ
ក្នុងដែងមល្លរដ្ឋកុសិនារា លើផែនថ្មដាម្លប់សាលព្រឹក្ស ។
ក្នុងឆ្នាំម្សាញ់វិសាខា ពេញបូណ៌អង្គារល្អពន្លឹក
រាត្រីខ្សោយហើយពេលទៀបព្រឹក ព្រះអង្គទ្រង់នឹកដល់និព្វាន ។
បច្ចូសម័យថ្ងៃជិតរះ ស្តេចទ្រង់បិទព្រះឱស្ឋចូលឈាន
ចេញហើយចូលទៀតទើបនិព្វាន និរោធក្នុងឈានជាចន្លោះ ។
នៃឈានទី ៤ នឹងទី ៥ កើតអស្ចារ្យមាំក្នុងគ្រានោះ
លោកធាតុទាំងម៉ឺនញ័រដូចគោះ ទៅខាងលើនោះដល់ស្ថានព្រហ្ម ។

ខាងក្រោមដល់រងបាតធរណី ញាប់ញ័រគ្រប់ទីស្ថានតូចធំ
ពួកមនុស្សទេវតាមារឥន្ទព្រហ្ម ទួញសោកស្រែកយំស្តាយសាស្តា ។
ពេលនោះមានផ្កានាគបុស្ស ជ្រុះរោយរាយចុះចាកសួគ៌ា
ទេវតានាំមកបាចបូជា ព្រះសពភគវាជាអស្ចារ្យ ។
សហម្បតីព្រហ្មសរសើរ ថាផុតដំណើរភពសង្សារ
ព្រះអង្គឈ្នះពួកបញ្ចមារ ស្តេចដាក់សង្ខារចូលនិព្វាន ។
ព្រះឥន្ទពោលថាអនិច្ចា សត្វក្នុងលោកាមិនទៀងប្រាណ
អម្បាលតួអង្គព្រះទ្រង់ញាណ គង់ចូលនិព្វានដូចនេះណា ។
អនុរុទ្ធថាព្រះតថាគត ផុតខ្យល់រលត់អស្សាសា
បស្សាសៈគ្មានសល់ត្រង់ណា ដូចលត់ជ្វាលាឥតនៅឡើយ ។
អានន្ទពោលថាព្រះសម្ពុទ្ធ ស្តេចនិព្វានផុតពភទៅហើយ
មានហេតុអស្ចារ្យខ្លាំងពេកហើយ កើតឱ្យព្រឺស្បែកព្រឺលោមា ។
មនុស្សទេវតាព្រាហ្មណ៍នឹងពួកក្សត្រ ក៏កើតវិបត្តិសោយសោកា
វៀរលែងតែអង្គអរហន្តា យំស្តាយសាស្តាព្រះទ្រង់ញាណ ។
ឱ! ព្រះសម្ពុទ្ធមកុដត្រៃលោក ម្តេចឡើយទ្រង់ជោគចូលនិព្វាន
ចោលពួកបរិស័ទច្រើនសែនលាន នរណាទូន្មានជួយព្រះអង្គ ។
យើងខ្ញុំជ្រកក្រោមម្លប់សាសនា សង្ឃឹមសាស្តាជួយស្រោចស្រង់
ដោយសារភេត្រាធមិព្រះអង្គ ម្តេចឡើយក៏ទ្រង់និព្វាននេះ ។
ស្តាយអើយស្តាយអង្គព្រះទ្រង់ញាណ មិនគួរនិព្វានអ្វីឆាប់ម្លេះ
ស្តាយណាស់ថ្លើមសួតស្ទើររបេះ ទ្រូងតឹងស្ទើរប្រេះទៀបមរណា ។
ស្តាយអើយស្តាយទ្រង់ធ្លាប់ប្រទាន ពុទ្ធដីកាទូន្មានយើងរាល់គ្នា
ស្តាយធ្លាប់ថ្វាយទាននឹងសាស្តា ស្តាយស្តាប់ទេសនាផ្ទាល់ព្រះអង្គ ។
ស្តាយអើយសែនស្តាយព្រះកាយទ្រង់ សាវ៏កធ្លាប់គាល់គង់របាង
ទ្រង់ជាប្រធាននៃពួកសង្ឃ ឥឡូវព្រះអង្គនិព្វានបាត់ ។
ឱ! ស្តេចមច្ចុមារកំណាច ម្តេចឡើយមិនខ្លាចហ៊ានមកកាត់
ព្រះជន្មព្រះពុទ្ធដូចសព្វសត្វ ឱ្យនិព្វានបាត់ទៅស្ងាត់ឈឹង ។

គ្មានចិត្តអាណិតចិត្តមេត្តា គ្មានចិត្តករុណាធ្វើយ៉ាងហ្នឹង
គ្មានគិតយោគយល់ថាទីពឹង ជាទីពុំនឹងយើងរាល់គ្នា ។
យើងខ្ញុំព្រះអង្គបាត់ទ្រង់ជោគ បីដូចផ្ទៃលោកបាត់សុរិយា
មានតែងងឹតឥតភ្លឺថ្លា ព្រោះម្ចាស់សាសនានិព្វាហើយ ។
យើងខ្ញុំអ្នកតែងនឹងថ្លៃគុណ សូមតេជះបុណ្យបានដល់ត្រើយ
ជួយឱ្យទុក្ខភ័យរោគសះស្បើយ ដរាបដល់ត្រើយនិព្វានហោង ។

## ចប់និព្វានសូត្រ តែប៉ុណ្ណេះ!

# ពិម្ពាពិលាប

## កាព្យពាក្យ ៧

នាកាលព្រះសម្ពុទ្ធជាម្ចាស់ បានត្រាស់ហើយស្ដេចមកសំដែង
ព្រះធម៌ទេសនានៅនាល្វែង ប្រាសាទកន្លែងព្រះបិតា ។
ព្រះបាទសទ្ធោទន៏ទតបរិស័ទ ឃើញបាត់តែនាងរត្នពិម្ពា
មិនឃើញនាងមកស្ដាប់ទេសនា រាជាទ្រង់ត្រាស់ប្រើទាសី ។
ឱ្យទៅអញ្ជើញព្រះពិម្ពា ឱ្យទ្រង់លីលាមកឆាប់ខ្មី
ថាដ្បិតភស្ដាជាស្វាមី ចក្រីមកគង់នៅប្រាសាទ ។
របស់ព្រះបិតាឯណោះ សូមនាងយាងចុះដោយខ្មីឃ្មាត
ប្រញាប់ប្រញាល់ណានាងនាថ ដ្បិតញាតិជួបជុំចាំតែនាង ។
ទាសីទៅដល់ក៏ពោលថ្លែង សំដែងរៀបរាប់ក្រាបទូលភ្លាង
ទៅតាមទំនងឥតមានឃ្វាង ព្រះនាងក៏ជ្រាបសព្វសេចក្ដី ។
ទង្គិះតានតឹងរឹងចង្អៀត ខំឆ្លៀតមានព្រះសវនីយ៏
ចំពោះទៅរកនាងទាសី ថាសូមប្រណីខ្ញុំផងរ៉ា ។

នាំពាក្យពិតត្រង់របស់ខ្ញុំ ទៅក្រាបបង្គំទូលបិតា
ឱ្យស្ដេចបានជ្រាបសព្វកិច្ចា កុំឱ្យភស្ដាស្ដេចរងចាំ ។
ព្រោះពិម្ពាខ្ញុំមិនសមស័ក្ដិ ជាស្រីអប្បល័ក្ខណ៍អ្នករងកម្ម
កើតកើ្ដអប្រិយអង្វែងឆ្នាំ រង់ចាំតែពេលក្ស័យជីវិត ។
បើព្រះអយ្យបុត្រទ្រង់ជ្រាបថា ពិម្ពាខត្តិយាជាមហេសី
កំសត់នៅក្នុងប្រាសាទបី ហេតុអ្វីក៏ស្ដេចមិនយាងមក ។
ឬទ្រង់ភ្លេចទីកន្លែងហើយ ម្ចាស់អើយម្ដេចទ្រង់មិនលៃលក
ប្រសិនបើទ្រង់គិតរិះរក គួរតែយាងមកដល់កន្លែង ។
បើច្នេះពិម្ពាសូមក្រាបលា បិតាមានគុណធ្ងន់ជាក់ស្ដែង
ព្រមទាំងភស្ដាជាគម្លែង ស្លាប់ចាកកន្លែងថ្ងៃនេះជាក់ ។
នៃនាងទាសីស្រីបំរើ ចូរកុំសើរើធ្វើអល់អាក់
ចូរទូលឱ្យគ្រប់កុំបីលាក់ តាមថ្នាក់ដូចយើងបានពណ៌នា ។
ទាសីក៏ក្រោកចាកអាសនៈ នាំពាក្យសច្ចៈនាងពិម្ពា
ដល់ហើយក៏ទូលព្រះរាជា តាមឃ្លាតឃ្លាតពាក្យតូចធំ ។
ព្រះបាទសុទ្ធោទនីជ្រាបតាមពិត ខិតចូលទៅជិតព្រះបរម
លើកហត្ថទាំងពីរថ្វាយបង្គំ ទូលផ្សំសេចក្ដីដូច្នេះថា ។
គួរណាស់ពេលនេះព្រះភគវ័ន្ត ស្ដេចទ្រង់និមន្តទៅប្រាង្គប្រា
សាទនាងពិម្ពាគ្រានេះណា ដ្បិតនាងសោកាអស់កាលវែង ។
ដូចកាលដែលទ្រង់យាងយាត្រា ទៅរកប្រាជ្ញាញាណនេះឯង
ពិម្ពាមានចិត្តគិតចំបែង យំសោកក្ដែងៗរាល់វេលា ។
បានដឹងដំណឹងដោយទេវបុត្រ ប្រាប់ថាចមមុឌិអត់ភោជនា

ស្គាំងស្គមស្លេកស្លាំងខ្លាំងមហិមា ដួលលើពសុធាមហាប្រថពី ។
ប្រាប់ថាទ្រង់រងទុក្ខពេកក្រៃ ស្មើរក្ស័យព្រះជន្មសូន្យសញ្ញី
ហើយប្រាប់បន្ស្យល់ដល់ទេវី កុំឱ្យនារីសោកឡឹនឡង់ ។
ពេលនោះពិម្ពានារីរ័ត្ន ស្មារតីស្មើរភ្លាត់ស្រីវរវង្ស
នាងអត់អាហារតាមព្រះអង្គ ចិត្តត្រង់នឹងទ្រង់ពេលណាស់ណា ។
ជូនកាលផ្ទំផ្ទាល់លើផែនដី ឱ្យដូចស្វាមីមិនរួញរា
ហេតុនេះគួរហើយព្រះភគវា មេត្តាពិម្ពាគ្រានេះឯង ។
ឯព្រះបរមពុទ្ធង្កុរ មានព្រះបន្ទូលសំរួលថ្លែង
ថាពិតមែនហើយព្រះគម្លែង ពិម្ពាចំបែងសង្រេងណាស់ ។
ពិម្ពាមានចិត្តទៀងត្រង់ជាក់ ស្មោះស្ម័គ្រឥតល្មៀងទេណាម្ចាស់
មិនត្រឹមតែក្នុងជាតិនេះច្បាស់ ចិត្តត្រង់យូរណាស់គ្រប់៧ជាតិ ។
ទើបទ្រង់ស្តេចយាងចាកដំណាក់ ព្រមទាំងសាវ័កដ៏សីហនាទ
លុះដល់ទៅជិតប្រាង្គប្រាសាទ ស្អាងស្អាតជាទីព្រះពិម្ពា ។
ហើយផ្តាំសារីបុត្រនិងមោគ្គល្លាន ថាក្រែងលោមានហេតុនានា
បើនាងពិម្ពាមកវន្ទា ស្រវាឱបបាទតថាគត ។
នោះអ្នកកុំឃាត់ពិម្ពារឡើយ ការនោះស្រេចហើយតែបរិសុទ្ធ
បើអ្នកឃាត់ខាំងនាងស្រយុត នឹងផុតរលត់ជីវិតបង់ ។
នឹងខូចប្រយោជន៏ច្រើនណាស់ណា ដែលយើងប្រាថ្នានឹងស្រោចស្រង់
ពិម្ពាជាស្រីមានចិត្តត្រង់ កុំឱ្យនាងបង់បាត់និស្ស័យ ។
ហើយព្រះទ្រង់ញាណឈានព្រះបាទ ឡើងកាន់ប្រាសាទប្រសើរក្រៃ
ព្រមទាំងបិតាសាវ័កថ្លៃ ព្រះចមភពត្រៃស្ថិតខាងក្រៅ ។

បិតាឱ្យហៅនាងពិម្ពារ ឱ្យយាងយាត្រាទាំងសុបសៅ
ថាដ្បិតស្តេចគង់ចាំខាងក្រៅ នាងនៅធ្វើអ្វីពិម្ពាអើយ ។
នាងនាថក៏ស្ទុះចេញប្រញាប់ ដល់ហើយឱបចាប់ព្រះគ្រានត្រើយ
ឱបបាទទាំងគូរមិនមានស្បើយ រួចហើយព្រះនាងទ្រៀងទូញថា ។
បពិត្រចមមកុដបំផុតលោក ពិម្ពាខ្ញុំសោកយូរណាស់ណា
តាំងតែពីកាលព្រះសាស្តា ស្តេចចេញបព្វជ្ជាចោលខ្ញុំទៅ ។
ខ្ញុំតែងទន្ទឹងរីងទន្ទេញ ទុក្ខម្នេញពេញម្នោពោពុះក្តៅ
តែងក្តួលរំជួលអួលមួមៅ គិតព្រះឆោមឆ្លៅពុំមានស្បើយ ។
ខ្ញុំឮដំណឹងដឹងមកថា សាស្តាស្តេចទ្រង់មិនសោយឡើយ
ស្តាំងស្គមដួលដេកក្ស័យទៅហើយ ម្ចាស់អើយពេលនោះខ្ញុំភាន់ភាំង ។
ខ្លួនខ្ញុំក៏មិនបានបរិភោគ សោយតែក្តីសោកជានិច្ច
ដោយនឹករលឹកទ្រង់យ៉ាងខ្លាំង ស្គមស្គាំងស្លេកស្លាំងទាំងរាងកាយ ។
ទើបទ្រង់ត្រាស់តបទៅនាងថា អើនាងពិម្ពានាងអធិប្បាយ
ត្រូវពិតមែនហើយដូចបរិយាយ នាងស្តាយនាងសោកខ្លាំងណាស់ណា ។
តែចូរនាងស្តាប់តថាគត នឹងពោលរលត់អស់ទុក្ខា
ឱ្យខកខះខនខានសោកា ដោយធម៌ទេសនាណាក្សត្រី ។
កាលព្រះពិម្ពាក្សាន្តយោបំ ក្រាបថ្វាយបង្គំដោយសិរី
សម្ងំសម្ងាត់ប្រុងស្មារតី អង្គព្រះជិនស្រីក៏ត្រាស់ថា ។
ធម៌ណាធ្វើសត្វឱ្យវិនាស វិបល្លាសប្រាស់ព្រាត់សង្ខារា
កើតហើយវិនាសជាធម្មតា ធម៌នោះឈ្មោះថាអនិច្ចំ ។
ធម៌ដែលធ្វើឱ្យសត្វលំបាក ឥតស្រាកឥតស្រាន្តបានទុក្ខខ្លាំង

ធម៌នោះមានឈ្មោះថាទុក្ខ កំលាំងខ្លាំងក្លាឥតថ្នឹមដល់ ។
ធម៌នោះមិនលុះអំណាចចិត្ត សព្វសត្វសង្ខារតាមថ្នាក់ថ្នល់
មិនស្តាប់បង្គាប់ប្រាប់បន្សល់ សំគាល់ឈ្មោះថាអនត្តា ។
នឹងថាជាធម៌សំរាប់ស្រុក មួយៗដោយមុខក្នុងលោកា
ឬធម៌សំរាប់ត្រកូលណា ប្តេជ្ញាដាច់មុខនោះគ្មានឡើយ ។
ជាធម៌ទូទៅគ្រប់ភូមិស្រុក ឥតមារើសមុខទេអ្នកអើយ
មិនមែនកំណត់យើងគេឡើយ រកត្រើយគេចវេះកម្របាន ។
សត្វដែលកើតក្នុងផលាលោក មានទុក្ខមានរោគច្រើនស្ថាន
ធម៌ទាំងបីបទកំណត់មាន ស្ថិតលើអង្គប្រាណសន្តានសត្វ ។
ហេតុនេះគួរហើយជាតិបណ្ឌិត ប្រុសស្រីយកចិត្តខំប្រតិបត្តិ
ខំប្រឹងរៀនសូត្រស្រូតកំចាត់ បំបាត់ឈ្មោះសត្វទើបសុខា ។
កើតឡើងមានធាតុមានឥន្ទ្រិយ៍ អង្គព្រះមុនីទ្រង់ត្រាស់ថា
ឈ្មោះសត្វនោះមានកន្លែងណា អនិច្ចាតែងមានកន្លែងនោះ ។
ទុក្ខំអនត្តាក៏តាមទៅ ហាក់ដូចសូមនៅនឹងពិគ្រោះ
ខុសត្រូវឱ្យសត្វឥតមានមោះ សត្វឥតដឹងសោះស្មានថាជា ។
ចប់ធម៌ទេសនាព្រះមុនី ពិម្ពាទេវីលុះសោតា
នាងថ្វាយបង្គំព្រះសាស្តា ជ្រះថ្លាក្នុងចិត្តឥតថ្នឹមបី ។
សង្ខេបសេចក្តីនៃនិទាន ដែលមានមកហើយក្នុងបាលី
ខ្លួនខ្ញុំតាក់តែងជាពាក្យស្តី ដើម្បីអ្នកស្តាប់កើតជ្រះថ្លា ។
ខ្ញុំសូមឧទ្ទិសចំណែកផល ជូនដល់មាតានឹងបិតា
នឹងលោកសប្បុរសទាំងអស់ គ្នាឱ្យបានសុខាតរៀងទៅ ។ **(ចប់)**

# ទំនួញព្រះអានន្ទ

## ភាពពាក្យ ៧

ដំណាលកាលអង្គព្រះសម្ពុទ្ធ ស្តេចទ្រង់ពិរុទ្ធសួរប្រស្នា
ចំពោះអានន្ទឱ្យដោះសារ ហើយព្រះសាស្តាស្តេចនិព្វាន ។
ដើមហេតុអានន្ទភាន់សញ្ញា ពិលាបសោកាស្តាយទ្រង់ញាណ
ដឹងច្បាស់ថាទ្រង់នឹងនិព្វាន អានន្ទគិតស្មានគ្មានទីពឹង ។
បរិទេវៈអ្នកទួញថា ឱព្រះសាស្តាស្តេចវិលវឹង
យាងចូលនិព្វានឲ្យានសូន្យឈឹង អស់ទីពុំនឹងងប់ុណ្ដឹងហើយ ។
ឱព្រះសម្ពុទ្ធបំផុតលោក មានជោគតេជៈណាម្ចាស់អើយ
បើទ្រង់និព្វានបាត់ទៅហើយ ម្ចាស់អើយសមសត្វស្ងាត់គ្រប់គ្នា ។
ដូចជាអានន្ទខ្ញុំនេះឯង ខានបានកោតក្រែងខានបានទស្សនា
ព្រះរូបព្រះឆោមព្រះសាស្តា ខានបានសិក្សាអាថិសេចក្តី ។
ខានបានត្រង់ត្រាប់ស្តាប់ឱវាទ អង្គព្រះមុនីនាថដូចប្រក្រតី
ខានចរបិណ្ឌបាតតាមជិនស្រី ខានស្ដីខានស្តាប់ធម្មកថា ។
អានន្ទមិនទាន់បានសម្រេចពិត អស់កិច្ចបព្វជិតក្នុងសាសនា
ឥឡូវថ្ងៃនេះព្រះសាស្តា ស្តេចនឹងយាត្រាចូលនិព្វាន ។
បពិត្រចមមកុដសុទ្ធិវង្ស មិនគួរបើទ្រង់នឹងនិរាណ
ចោលអស់បរិស័ទណាទ្រង់ញាណ យាងចូលនិព្វានស្ថានសុខា ។
ព្រះអង្គទ្រង់សួរអានន្ទមុន ដើម្បីជាគុណដ៏ថ្លៃថ្លា
បញ្ជាក់សេចក្តីនៃពុទ្ធដីកា ដោយទ្រង់ប្រាថ្នាស្តារការស្តាយ ។
អានន្ទចូរអ្នកតាំងចិត្តទុក អ្នកកុំអផ្សុកចូរមកអាយ

យើងសួរបញ្ហាក់ពីរូបកាយ បំណាច់អ្នកស្តាយកាយនេះឯង ។
អានន្ទអើយកាលព្រះបិតា និព្វាននោះណាមានជាក់ស្តែង
ពេលនោះគឺបាអានន្ទឯង ក៏បានឃើញស្តែងដោយន័យនា ។
សាវ័កអ្នកស្តាប់ពាក្យឱវាទ មូលមកសន្និបាតពេញត្រៀបត្រា
អស់ពួកក្សត្រីនឹងក្សត្រា មកស្តាប់ទេសនាក្នុងគ្រានោះ ។
ក្សិណនោះឯស្តេចមច្ចុរាជ អង់អាចឈ្លានពានគ្មានពិគ្រោះ
ឥតកោតញញើតបន្តិចសោះ សង្កត់ចំពោះព្រះអង្គា ។
នាំយកជីវិតព្រះបិតុរង្គ ឥតមានបង្អង់ពេលវេលា
ដោយឥតអៀនខ្មាស់អ្នករាល់គ្នា ពិគ្រានោះលុះដល់ឥឡូវ ។
ពេលនោះអស់ពួកញាតិវង្ស សឹងទ្រង់យោបំយំពេកកូវ
សោកស្តាយព្រះអង្គតែសព្វផ្លូវ ស្តេចត្រូវមរណៈធ្លាក់ជីវិត ។
តថាគតទេសនាពន្យល់ ប្រាប់ដល់ពួកញាតិនឹងទេពី
ដោយធមិបីម៉ាត់កាត់ផ្តាច់ទី ធូលីប្រាសចាកស្រាកទុក្ខស្បើយ ។
ឯធមិបីម៉ាត់គឺអនិច្ចំ ទុក្ខំអនត្តាណានន្ទអើយ
អ្នកភ្លេចបាត់សោះអស់ទៅហើយ ឬមួយនៅឡើយឥតហ្មងសៅ ។
ចំណែកប៉ែកខាងធមិវិន័យ គួរអ្នកកែខៃគិតឱ្យជ្រៅ
បើទុកជាយើងនិព្វានទៅ អ្នកនៅឯក្រោយក៏មិនថ្វី ។
ធមិនឹងវិន័យថ្លៃវិសេស រម្ងាប់កិលេសបាបអប្រិយ
បើចិត្តអ្នកប្រុងផ្ចង់ស្មារតី មិនមែនក្រក្រីទេអានន្ទ ។
អានន្ទក្រាមទូលតបវិញថា ដែលទ្រង់ករុណាទោសស្រាលធ្ងន់
ប្រាប់វិន័យច្រើនលើសលន់ អានន្ទចាំបានឥតភ្លាំងភ្លាត់ ។

ហេតុនេះអានន្ទមិនជិនណាយ　　ចេះនឹកស្តាយព្រះភគវ័ត
មិនចង់ឱ្យទ្រង់បែកប្រាសព្រាត់　　ខ្វាយខ្វាត់ចាកខ្ញុំទេទសពល ។
ព្រោះធ្លាប់បានស្តាប់ទាំងយប់ថ្ងៃ　　អង្គព្រះចមត្រៃស្តេចពន្យល់
ឱ្យបានដឹងសព្វកងកុសល　　ហេតុផលទាំងល្អអាក្រក់ផង ។
ទ្រង់ត្រាស់តបទៅព្រះអានន្ទ　　កុំឱ្យអាក់អនចិត្តសៅហ្មង
ព្រោះរូបយើងឯងមិនអាចឆ្លង　　កន្លងសេចក្តីស្លាប់មរណា ។
អានន្ទអើយរូបតថាគត　　បានឈ្មោះប្រាកដថាជរា
ម្តេចអ្នកសោកស្តាយកាយគ្រាំគ្រា　　មិនជាប្រយោជន៍ប៉ុន្មានឡើយ ។
កាយនេះប្រៀបដូចរទេះចាស់　　ដែលគេប្រើប្រាស់ឥតល្ហែល្ហើយ
អបស្មបគ្រប់ពេលឥតមានស្បើយ　　គ្រាន់ហើយទើបបរត្រដរទៅ ។
តថាគតឯងក៏ដូច្នេះ　　អបស្មបកាយនេះឱ្យគង់នៅ
ដោយឥទ្ធិបាទ៤នោះកូវ　　បានជាគង់នៅដល់ទីនេះ ។
មួយទៀតធម៌ក្តីវិន័យក្តី　　អានន្ទកុំបីគិតសង្ស័យ
ថាក្រែងវិបត្តិស្ងាត់ត្រឹមណេះ　　អានន្ទផុតចេះត្រឹមហ្នឹងហើយ ។
មគ្គផលឥតមានកាលរារាំង　　ឃាត់ខាំងនិស្ស័យនៃសត្វឡើយ
អំណើះឥតពីយើងទៅហើយ　　ធម៌វិន័យហើយជាគ្រូអ្នក ។
បរិស័ទទាំង៤ឯណាមួយ　　បានស្ម័យដម្កល់ចិត្តស្មោះស្ម័គ្រ
ប្រតិបត្តិតាមធម៌សត្រជាក់　　តាមថ្នាក់ភេទភូមិរបស់ខ្លួន ។
បរិស័ទនោះឈ្មោះថាគោរព　　ឆ្ពោះព្រះចមភពយ៉ាងសមសួន
ដោយការបូជាដ៏មាំមួន　　ត្រូវក្បួនបូជាដ៏ឧត្តម ។
ឈ្មោះថារាប់អានតថាគត　　ប្រតិបត្តិហ្មត់ចត់យ៉ាងសមរម្យ

អានន្ទអើយអ្នកកុំបីយំ　　គួរខំប្រតិបត្តិកាត់អវិជ្ជា ។
ចន្លោះពាក្យពោលព្រះសម្ពុទ្ធ　　ចមមុុដទ្រង់ផ្អាក់ការសន្ទនា
ទ្រង់បើកឱកាសពេលវេលា　　ដល់ភិក្ខុរាល់គ្នាសួរព្រះអង្គ ។
តែក្នុងពេលនោះភិក្ខុបរិសទ្យ　　ស្ងៀមស្ងាត់រាល់គ្នាដោយស្ដាយទ្រង់
ហាក់បាត់ស្មារតីគ្រប់ៗអង្គ　　ទើបទ្រង់បញ្ជាក់សេចក្ដីថា ។
ហន្ទះអើភិក្ខុទាំងឡាយអើយ　　យើងលាអ្នកហើយទាំងអស់គ្នា
មិនមានបង្អង់ពេលវេលា　　យើងនឹងគមនាចូលនិព្វាន ។
ដ្បិតសង្ខារធម៌មិនទៀងទាត់　　កើតហើយតែងភ្លាត់ជាមិនខាន
ឥតមានសង្ខារណាចៀសបាន　　កើតប្រាណមកហើយតែងប្រាស់ព្រាត់ ។
តុម្ហេនៃអស់លោកទាំងឡាយ!　　គួរខំខ្នះខ្នាយប្រុងប្រយ័ត្ន
កុំធ្វេសប្រហែសចូរខំហាត់　　រៀនសូត្រមធ្យ័តដោយប្រឹងប្រែង ។
ព្រោះថាធម៌ធ្វេសនេះជាធំ　　ជាគុម្ពជាគល់បារនោះឯង
សត្វដែលធ្វើបាបបានឥតក្រែ　　ព្រោះធម៌ធ្វេសក្លែងខ្លាំងក្លៀវក្លា ។
ម្យ៉ាងទៀតធម៌ធ្វេសនេះជាមូល　　អាចចាប់បញ្ចូលអស់សត្វា
ឱ្យបាននាមឈ្មោះថាមរណា　　ប្រែថាធ្វើសត្វឱ្យកើតស្លាប់ ។
បញ្ចប់សេចក្ដីនៃដំណាល　　ពីកាលអានន្ទយំរៀបរាប់
សង្ខេបប៉ុណ្ណោះមិនបានជាប់　　ដំណើររៀបរាប់ចប់ហើយហោង ។

**ចប់　ទំនួញព្រះអានន្ទ!**

# បច្ឆឹមពុទ្ធវចនៈ

## បទព្រហ្មគិត

យោវរ៉ាអានន្ទអើយ នៃបាអើយមកអាយរ៉ា
តថាគតនឹងមរណា ចាកចោលបាមិនខានឡើយ ។
ចូរបានៅឱ្យសុខ កុំជាទុក្ខណាបាអើយ
តថាគតលាអ្នកហើយ កុំសោកឡើយណាអានន្ទ ។
អង្គអញតថាគត នឹងរំលត់អស់បញ្ចក្ខន្ធ
នៅចុះណាអានន្ទ ខំគ្នេរគ្នាន់ក្នុងអង្គប្រាណ ។
ខ្លួនអ្នកនៅសព្វថ្ងៃ មានឧបមេយ្យ
ដូចជាចានមិនស្ថិតស្ថេរប៉ុន្មាន គង់នឹងបានវិនាសទៅ ។
ហេតុនេះបាអានន្ទ ចូរគ្នេរគ្នាន់គិតឱ្យជ្រៅ
ឥតពីតថាគតទៅ អ្នកឯងនៅថៃសាសនា ។
សាសនាតថាគត ស្ថិតប្រាកដនឹងអ្នកណា
ដែលមានចិត្តជ្រះថ្លា ប្រព្រឹត្តត្រូវតាមលំអាន ។
គ្រានេះតថាគត នឹងរំលត់ខន្ធនិព្វាន
ដោយជរាចូលរុករាន ទន្ទ្រានមកផ្តាច់សង្ខារ ។

## ចប់ បច្ឆឹមពុទ្ធវចនៈ!

# បណ្ដាំនាងមហាមាយាទេវី ចំពោះនាងគោតមី

## ពាក្យកាព្យបុរាណ

ហៃនាងគោតមីស្រីប្អូនអើយ ប្អូនអើយចូរចាំបណ្ដាំណា
បងសូមផ្ញើផ្ដាំលើកនិដ្ឋា ចូរប្អូនមេត្តាត្រាប្រណី ។
បងបានចម្លងព្រះអយ្យបុត្រ កំណត់បានត្រឹម៧ថ្ងៃ
ប្រាំពីរទិវាណាប្អូនស្រី ត្រូវក្ដីមរណៈមកស្ទាក់កាត់ ។
ស្រីអើយកូននេះអស្ចារ្យណាស់ ពួកហោរាសាស្ត្របានថ្វាយថ្វាត់
នាមថាសិទ្ធត្ថតាមបញ្ញត្តិ អ្នកញ៉ាំងពួកសត្វឱ្យចំរើន ។
អយ្យបុត្រយើងនេះនឹងបានត្រាស់ ដឹងសព្វគ្រប់សាសន៍ដោយក្រវើន
បានជាទីពឹងដល់អ្នកច្រើន ចំរើនសុខសព្វមនុស្សទេវតា ។
ប្អូនអើយសូមប្អូននាងតាំងចិត្ត អាណិតក្មួយនេះដោយករុណា
បំបៅបីពរសព្វប្រការ ធ្វើដោយហត្ថារបស់ខ្លួន ។
ស្រីកុំបណ្ដោយឱ្យទាសា ទាសីឈ្មោះណាក្រៅពីស្ងួន
ធ្វើដោយដៃឯងយ៉ាងមាំមួន ទើបឈ្មោះថាស្ងួនមេត្រីពិត ។
ផ្ដាំស្រេចនាងមហាមាយា នាងក៏មរណាអស់ជីវិត
ទៅកាន់ទេវលោកឋានតុសិត វិចិត្រដោយឫទ្ធិអនេកា ។
ន័យខ្លះថានាងមហាមាយា ទៅកើតនៅនាត្រៃត្រឹង្សា
បានឮដំណឹងដោយទេវតា ប្រាប់ថាអយ្យបុត្រល្អពេកក្រៃ ។
បានជាក្នុងពេលព្រះមហាក្សត្រ ទ្រង់ត្រាច់រង្គត់ក្នុងដងព្រៃ
តាំងមហាបធានមានបួនន័យ ក្នុងព្រៃឧរុវេលក្រុងគយា ។
ព្រះកាយស្គមណាស់នៅតែឆ្អឹង ព្រះនេត្រាល្អក់ស្លឹងហួសពណ៌នា

ទ្រង់ដួលក្រាបចុះលើពសុធា សោយទុក្ខវេទនាស្ទើរក្ស័យជន្ម ។
ពេលនោះសិរិមហាមាយា ចុះចាកសួគ៌ាមកគយគន់
ទតសព្វរូបរាងព្រះភគវន្ត ដូចខ្ញុំនិពន្ធរួចមកហើយ ។

## ចប់ បណ្ដាំនាងសិរិមហាមាយាទេវី!

## ពិម្ពាវិយោគ

## ពាក្យអាព្យប្វរាណ

ដំណាលកាលអង្គព្រះអយ្យបុត្រ ស្ដេចទ្រង់យាងផុតចាកដំណាក់
ក្រោយនោះពិម្ពាជាឯកអគ្គ មហេសីទ្រង់ភ្ញាក់ចាកនិទ្រា ។
បំព្រាងរស្មីភ្លឺស្រាង១ ព្រះនាងទ្រង់យាងចេញចរលី
ទ្រង់ស្រប់ព្រះភក្ត្រដោយវារី ស្រេចហើយទេវីចូលទៅគង់ ។
ព្រះនាងទ្រង់ពរាជកុមារ ដោយការប្រាថ្នានឹងផ្ចិតផ្ចង់
លើកឡើងផ្ទួតទឹកជំរះអង្គ នឹងទ្រង់ប្រដាប់សំរាប់បុត្រ ។
ស្រាប់តែទាសីស្រីបំរើ មកក្រាបទូលស្ទើញ័រផុត១
បរិយាយរ៉ាយរាប់ដោយតក់ស្លុត ភិតភ័យស្រយុតហើយថ្លែងថា ។
បពិត្រព្រះនាងសូមទ្រង់ជ្រាប នូវភាពដំណើររាជភស្ដា
មិនដឹងជាស្ដេចត្រាច់យាត្រា បាត់ទៅឯណាពុំឃើញឡើយ ។
ព្រះនាងបានឮទាសីថ្លែង ព្រះទ័យចំបែងឥតមានស្បើយ
គិតថាព្រះស្វាយមីអើយ ម្ដេចឡើយទ្រង់កាត់ក្ដីស្នេហា ។
ព្រះនាងទ្រង់សោកបោកព្រះកាយ ដោយស្ដាយពន់ពេកឥតឧបមា
ទ្រង់សោយវិយោគពិលាបថា ឱព្រះភស្ដាម្ចាស់ប្អូនអើយ ។

ទ្រង់មានបើអាក់ព្រះទ័យា នឹងអ្វីបានជាមិនប្រាប់ឡើយ
បើទ្រង់ជិនណាយពិម្ពាហើយ ម្ចាស់អើយពិម្ពាអត់បើថា ។
ប៉ុន្តែគួរទ្រង់ជូនប្អូនទៅ លំនៅព្រះវររាជបិតា
ធ្វើម្ដេចព្រះទ័យអស់ស្នេហា ពិម្ពាឥតថាទេព្រះគុណ ។
នេះម្ដងម្ដេចឡើយធ្វើដូច្នេះ ទ្រង់ធ្វើយ៉ាងនេះឱ្យស៊យស៊ុន
ឱ្យពិម្ពាបានទុក្ខទារុណ ព្រោះតែព្រះគុណពិតប្រាកដ ។
ម្លោះហើយពិម្ពាអស់បានសុខ មានតែក្ដីទុក្ខជាកំណត់
ឱខ្លួនអញអើយនេះហៅព្រាត់ ចាកព្រះចក្រព័ត្តិបុត្រក្សត្រា ។
ឱះឱរាហុលមាសម្ដាយអើយ កូនអើយកូននៅតូចណាស់ណា
មិនទាន់ដឹងយល់កលកិច្ចា បិតាចាកចោលឥតអាល័យ ។
ឱព្រះអយ្យបុត្រមកុដពេជ្រ បើស្ដេចទៅហើយបានអាស្រ័យ
បានសុខសប្បាយព្រះហឫទ័យ ឥតភ័យនោះខ្ញុំអរណាស់សា ។
ប្រសិនបើទ្រង់ទីវង្គត ខ្ញុំប្អូនសូមអត់ផ្ដាច់ជីវ៉ា
ជីវិតទៅតាមព្រះជេដ្ឋា យ៉ាងណាក៏ដោយចុះមិនស្ដាយ ។
ស្ដាយអើយសែនស្ដាយស្ដេចយាងបាត់ មិនសមបើព្រាត់ក្សត្រឆោមឆាយ
ឱ្យពិម្ពាខ្ញុំនៅមេម៉ាយ កាយអើយកាយកម្មពីបុព្វជាតិ ។
សប្បុរសទាំងឡាយចូរស្ដាប់ចុះ រឿងនោះត្រូវណាស់ឥតវវាត
ដល់រូបស្រីប្រុសមិនខុសឃ្លាត ដល់ញាតិព្រៀងលានគ្រប់ៗគ្នា ។
មានខ្លះស្លាប់ប្ដីប្រពន្ធកូន ស្លាប់បងស្លាប់ប្អូនម្ដាយមីងមា
គ្រប់ភូមិគ្រប់ស្រុកទុក្ខវេទនា គ្រប់គ្នាទាំងអស់ឥតមានសល់ ។
ព្រាត់ប្រាស់និវាសរាល់ភូមិឋាន ឥតខានដល់ម្នាក់សព្វសកល

សឹងកើតទុក្ខសោករោគាផ្តល់ ជាផលនៃជាតិគ្រប់រូបា ។
ជាតិកើតមកពីក្តីចំណង់ ដែលចង់មិនចេះធុញត្រង់ណា
ចំណង់នោះពោលគឺតណ្ហា ធ្វើសត្វគ្រប់គ្នាឱ្យបានទុក្ខ ។
ទុក្ខទាំងអស់នេះមានអំណាច អង់អាចទន្ទ្រានកំចាត់សុខ
សព្វសត្វតូចធំមិនរើសមុខ សុទ្ធសឹងបានទុក្ខគ្រប់ៗគ្នា ។
ហេតុនេះបានជាព្រះមហាក្សត្រ ទ្រង់កាត់ព្រះទ័យឥតរួញរា
ចោលអគ្គមហេសីស្រីពិម្ពា ចេញសាងបព្វជ្ជាជាអវសាន ។
សម្បត្តិសម្បូណ៌ឥស្សរស័ក្តិ គ្មានទាក់ព្រះទ័យព្រះអង្គបាន
សូម្បីរាហុលបុត្រកល្យាណ ក៏ថ្កានចេញចោលឥតអាល័យ ។
សប្បុរសលោកអ្នកមានឧបាយ គួរគិតខ្វល់ខ្វាយឱ្យឆ្ងាយក្រៃ
ថាក្តីព្រាត់ប្រាស់និរាសក្ស័យ មានក្នុងភពត្រៃគ្រប់រូបា ។
មិនមែនមានតែត្រឹមនាងនាថ ដែលប្រាស់ឃ្លាឃ្លាតព្រះភស្តា
ដោយស្តេចចាកចោលរាជសីមា នាងមានទុក្ខាប៉ុណ្ណោះឡើយ ។

**ចប់ពិម្ពាពិលាប!**

ææææææ

# ព្រះពោធិសត្វយាងចេញសាងផ្នួស

## ពាក្យកាព្យបុរាណ

ដំណាលកាលអង្គព្រះសារពេជ្រ ទ្រង់ស្ដេចចៀសចេញចរលីលា
ចាកក្រុងកបិលភស្ដុភារា ចោលនាងពិម្ពាឥតអាល័យ ។
ទ្រង់នឹករលឹកឆ្ពោះនេក្ខម្មា ដោយទ្រង់ជ្រះថ្លាអស្ចារ្យក្រៃ
ដែលទ្រង់បានទតឃើញពីថ្ងៃ ព្រះទ័យអាល័យនឹកមិនបាត់ ។
បើច្នោះគួរហើយចេញបព្វជ្ជា វេលាកណ្ដាលអធ្រាត្រស្ងាត់
មិនឈប់បង្អង់ក្រែងវិបត្តិ មកស្កាត់ដំណើរនៃព្រះអង្គ ។
ស្ដេចទ្រង់ត្រាស់ហៅឆន្នអាមាត្យ ឱ្យខំសង្វាតទាន់ចំណង់
តែងគ្រឿងអស្សតរល្អត្រចង់ នាំមកថ្វាយទ្រង់គង់ប្រថាប់ ។
ដ្បិតទ្រង់នឹងយាងក្នុងរាត្រី ឥតបីបង្អង់ព្រោះចង់ឆាប់
ទាន់ស្ងាត់បាត់មនុស្សនិងសួរស័ព្ទ ប្រញាប់រួសរាន់ទាន់វេលា ។
ហើយទ្រង់យាងទៅឯប្រាសាទ ស្អាងស្អាតរបស់ព្រះពិម្ពា
ដោយចង់បីពរបុត្រពុំងារ នាមារាហុលដ៏និយម ។
លុះឃើញនាងនាថផ្ដេកបុត្រា គងលើហត្ថាទ្រង់សែនខ្វល់
គិតថាបើអញចូលទៅដល់ ក្រែងពាល់ភ្ញាក់ចាកនិទ្រា ។
អាត្មានឹងដាច់ចាកបំណង ដែលប៉ងនឹងចេញចាកភារា
ណ្ហើយចុះកូនប្រុសឪពុកលា អ្នកទៅបព្វជ្ជាណាកូនអើយ ។
បើយើងបានត្រាស់ជាព្រះពុទ្ធ ចំហុតក្នុងលោកបានដល់ត្រើយ
នៃពោធិញ្ញាណកាលណាហើយ បាអើយបិតាទ្រង់ត្រឡប់ ។
មកឱ្យបានជួបឃើញមុខបា ដោយក្ដីស្នេហាបាសំណប់

ស្រឡាញ់បាណាស់ឥតមានស្អប់ មុខជាត្រឡប់ពុំខានឡើយ ។
ហើយទ្រង់ក៏យាងចាកដំណាក់ ស្រពោនព្រះភក្រ្តឥតមានស្បើយ
ទ្រង់ត្រាស់ថាឱរាហុលអើយ កូនអើយបានៅឱ្យសុខា ។
ហើយទ្រង់ក៏ចេញទាំងអធ្រាត្រ មានឆន្នអាមាត្យជាសេនា
ជូនព្រះមហាក្សត្រចាករដ្ឋា ឆ្ពោះអនោមាមហានទី ។
ដល់ហើយទ្រង់កាត់ព្រះកេសា បព្វជ្ជាក្បែរស្ទឹងមហាវារី
ប្រទានអស់គ្រឿងល្អសោភី ឱ្យឆន្នចរលីត្រឡប់ចុះ ។
ទ្រង់សោយវិមុត្តិ៧ថ្ងៃ ក្នុងព្រៃអម្ពុវ័នឆ្នេរស្ទឹងនោះ
ទ្រង់ឥតមានសោយអាហាសោះ ព្រោះអរចំពោះតែនេក្ខម្មា ។
ចាប់ផ្តើមតាំងតែពីថ្ងៃនោះ ទ្រង់ឆ្ពោះតម្រង់ព្រៃព្រឹក្សា
លែងមានអាល័យដល់សីមា ក្នុងអរញ្ញវាំងឯកឯង ។
ទ្រង់តាំងមហាប្រធានធំ ដោយទ្រង់និយមគិតតាក់តែង
ឥតមានរន្ធត់តក់ស្លុតក្រែង ទ្រង់តែងខំប្រឹងទាំងយប់ថ្ងៃ ។
ដំបូងទ្រង់ប្រើខ្យល់ចេញចូល ឱ្យមូលប្រមូលទៅតាមផ្ទៃ
លុះដល់ខ្យល់ជ្រួលរំជួលក្រៃ ក្សត្រថ្លៃស្ទើរក្ស័យព្រះជន្មា ។
ទើបទ្រង់បង្វែរអស្សាសៈ ព្រមទាំងបស្សាសៈវាតា
ឱ្យបក់ទៅតាមព្រះសិរសា ដោយទ្រង់ប្រាថ្នាចង់បានត្រាស់ ។
ដំណើរខ្យល់ចេញនិងខ្យល់ចូល ដើរមូលត្រកូលមិនវិបល្លាស
ទៅតាមទំនងដំណើរចាស់ ទើបមិនប្រែប្រាសខុសធម្មតា ។
តែក្នុងពេលនោះព្រះអយ្យបុត្រ ចមមកុដធំបំផុតត្រៃលោកា
ទ្រង់ដឹកល់ខុសផ្លូវបញ្ញា ទើបព្រះសាស្តាក្របានត្រាស់ ។

ដរាបទ្រង់អត់មិនសោយភត្ត ព្រះកាយធំធាត់ប្រែក្រឡាស់
ស្គមស្គាំងស្លេកស្លាំងដូចរូបចាស់ គួរណាស់សង្វេគពន់ពេកក្តាត់ ។
ពេលមួយទ្រង់យាងទៅបង្គន់ ទោទន់ស្រពន់អង្គមហាសត្វ
ព្រះបាទទាំងពីរព្រះភគវ័ត ទ្រង់ភ្លាត់ដួលដាបដល់ផែនដី ។
តទាគ្រានោះព្រះចមមកុដ ទ្រង់ស្លុតស្រយុតភ្លាត់ស្មារតី
ទេវបុត្រយកពិណមានខ្សែបី ដេញថ្វាយជិនស្រីជាប្រស្នា ។
ព្រះអង្គក៏មានសតិតាំង សំកាំងគង់គិតក្នុងចិន្តា
ហើយទ្រង់ក៏យល់កលកិច្ចការ សាស្តាកំណត់កត់ហេតុបាន ។
ភិក្ខុទាំង៥ចាំបំរើ មានចិត្តស្មោះស្មើទាំង៥ប្រាណ
ពេលនោះនាំគ្នាគ្រាប៉ីទ្រង់ញាណ នាំទៅទីឋានសម្រាន្តរម្យ ។
រៀបរាប់ចាប់ផ្តើមតាំងអំពី ព្រះមុនីមុនិន្ទពិនគោតម
ព្រះអង្គតាំងមហាប្រធានធំ ប្រឹងខំអស់៦វស្សា ។
កិច្ចដែលទ្រង់ផ្គងនូវអំពើ គឺធ្វើដោយមានព្រះឧស្សាហ៍
ឈ្មោះថាធ្វើទុក្ករៈកិរិយា ជាមហាវិរិយៈឥតផ្ទឹមបី ។
ប្រែថាអំពើកម្រក្តាត់ សព្វសត្វគេឃើញក្នុងលោកិយ
ត្រាប់តាមតួរអង្គព្រះជិនស្រី ក្រក្រីនឹងធ្វើពុំបានឡើយ ។
ឆ្នាំវកចូលមកគំរប់ជា ប្រាំមួយវស្សាបរិបូណ៌ហើយ
បានត្រាស់ប្រាកដដល់កោះត្រើយ និព្វានលំហើយស្បើយទុក្ខា ។
ត្រាស់ស្រេចទ្រង់ធ្វើកិច្ចទាំងប្រាំ រាល់ឆ្នាំតិថីនៃមាសា
ឥតមានបង្អង់ត្រង់ពេលណា សព្វទិនទិវារាត្រីស្ងាត់ ។
ទីមួយព្រះអង្គយាងបិណ្ឌបាត សង្វាតសន្តោសប្រោសមនុស្សសត្វ

ក្នុងខាងដើមថ្ងៃមិនដែលបាត់ ដើម្បីប្រោសសត្វចំណែកមួយ ។
ទីពីរព្រះអង្គទ្រង់ទេសនា ប្រោសសត្វរាល់គ្នាដោយឥតព្រួយ
សូរសៀងសំឡេងពិរោះស្រួយ ថ្ងៃមួយតែពេលរសៀលពិត ។
ទីបីទ្រង់ត្រាស់ប្រៀនប្រដៅ ភិក្ខុល្វង់ខ្លៅពាលបណ្ឌិត
ក្នុងពេលព្រលប់យប់ងងឹត តាមពិតដូចបានពោលពណ៌នា ។
ទីបួនកណ្ដាលអធ្រាត្រស្ងាត់ អង្គព្រះភគវ័តជាសាស្ដា
ទ្រង់ដោះប្រស្នានៃទេវតា ដែលមកបុច្ឆាក្នុងពេលនោះ ។
ទីប្រាំសម្ដេចអាតិច្ចវង្ស ស្ដេចទ្រង់ប្រមើលមើលសព្វសុស
ឥតមានទើសទាល់សល់កៀនកោះ ឃើញឆ្លុះនិស្ស័យនៃសត្តា ។
ក្នុងពេលបំព្រាងស្វាងរង្សី រស្មីអរុណភ្លឺជ្រះថ្លា
គឺពេលដែលយើងធ្លាប់ហៅថា បែកបច្ចូសាណាអ្នកអើយ ។
អស់លោកអ្នកនាងទាន់សាសនា គួរតែជ្រះថ្លាកុំកណ្ដើយ
បើបានដឹងឮដូច្នេះហើយ លោកអ្នកនាងអើយកុំសង្ស័យ ។
គួរគិតថាឱ!ព្រះសុគត ស្ដេចទ្រង់រលត់ខន្ធប្រល័យ
យាងចូលនិព្វានគ្មានទុក្ខភ័យ យូរថ្ងៃយូរខែយូរឆ្នាំសល់ ។
តែទ្រង់បានផ្ដាំនឹងអានន្ទ ប្អូនព្រះភគវ័ន្តដ៏និមល
ថានៃអានន្ទអ្នកកុំឆ្ងល់ មគ្គផលតាំងនៅជាធម្មតា ។
អ្នកថប់ក្រែងថាគ្មានច្បាប់ វិន័យប្រញប្តនិងធម្មា
តថាគតបានពោលពណ៌នា ក្នុងគ្រាមុនៗរួចមកហើយ ។
អានន្ទចូរអ្នកតាំងចិត្តទុក ឱ្យបានសប្បាយណាអ្នកអើយ
អ្នកកុំធុញថប់បារម្ភឡើយ ចូរស្បើយទុក្ខទៅកុំសោកា ។

សប្បុរសទាំងអស់ទោះប្រុសស្រី គប្បីគិតចុះគ្រប់រូបា
យើងមិនបានទាន់ព្រះសាស្តា ទាន់តែសាសនានៃព្រះអង្គ ។
តែទុកដូចជាយើងបានទាន់ ជួបព្រះភគវ័ន្តកាលនៅគង់
ព្រោះយើងរៀនធម៌ដោយផ្ចិតផ្ចង់ ឥតបីលះបង់ចាកសទ្ធា ។
កុំធ្វើចិត្តទ្រឹស្តដូចតិរ្ថិយ មិនជឿសេចក្តីព្រះសម្មា
ចេះមួយតែត្មះនិងនិន្ទា ដល់គ្នាអ្នករៀនផងទាំងឡាយ ។
ថាគ្មានអ្នកណាទាន់ព្រះត្រាស់ កុំអួតថាច្បាស់មកបរិយាយ
ពួកយើងមិនជឿលេងងាយៗ ដូចអ្នកអធិប្បាយទេអ្នកណា ។
ឱ!អស់សប្បុរសសាធុជន នេះជាពាក្យធ្ងន់ប្រាកដជាក់
សប្បុរសដែលគិតឃើញជ្រៅរាក់ កុំដាក់ពាក្យតបទៅនឹងគេ ។
គិតតែនាំគ្នាខំឧស្សាហ៍ ពេលណាឱកាសគួររិះរេ
រករៀនសូត្រទៅកុំដូចគេ កុំនៅទំនេរនាំឱ្យល្ងង់ ។
ល្ងង់នេះឯងហើយនាំពួកសត្វ ឱ្យបានវិបត្តិខ្ចាប់ពូជពង្ស
សត្វដែលវិលវល់ក្នុងអន្លង់ ព្រោះតែក្តីល្ងង់គឺអវិជ្ជា ។
សង្ខេបសេចក្តីតែប៉ុណ្ណេះ ទុកស្លេះបញ្ឈប់គ្រប់ឃ្លោងឃ្លា
ពាក្យទាំងប៉ុន្មានដែលពណ៌នា បរិបុណ្ណាបរិបូណ៌ហោង ។

## ចប់ សត្តុប្បញ្ញាវ!

ពាក្យកាព្យទាំងឡាយនេះ ជាកាព្យបុរាណបានតែងមកតាមរឿងពុទ្ធប្បវត្តិ តាំងពីព្រះអង្គនៅជាព្រះពោធិសត្វ ហើយបានចេញសាងបព្វជ្ជា រហូតដល់បានត្រាស់ជាព្រះពុទ្ធ និង បរិនិព្វាន ។ ដើម្បីទុកឱ្យកូនខ្មែរ គ្រប់ជំនាន់ស្វែងយល់នូវវិស័យព្រះពុទ្ធសាសនា ក៏ដូចជាការធ្វើកុសលសំរាប់បច្ឆាជនគ្រប់រូបផងដែរ ជាពិសេសគឺស្ពាននៃបុគ្គលម្នាក់ៗផ្ទាល់ខ្លួន ។

# ពុទ្ធបាទ ៥ ឋាន

## បទភុជង្គលីលា

ព្រះទសពលញ្ញាណ ជិតចូលនិព្វាន ទ្រង់មានមេត្តា
ករុណាសាយសព្វ គន្ធព្វអសុរា គ្រុឌនាគទេវតា
សត្វមនុស្សប្រុសស្រី ។

ទ្រង់ប្រោសប្រទាន ព្រះបាទ ៥ ឋាន ទុកឱ្យវន្ទិយ
ព្រះបាទមួយក្នុង ចមចុងគិរី សុវណ្ណមាលី
ជាទីកំណត់ ។

ព្រះបាទសោភា មួយស្ថិតនៅនា សុវណ្ណបពិត
មួយស្ថិតនៅនា លង្កាប្រាកដ លើភ្នំសន្ទតិ
សុមនកូដគាប់ ។

ព្រះបាទសួស្តី មួយនៅបូរី យោនកះស្រេចស្រាប់
អ្នកនគរស្រុក យកទុកសម្រាប់ រកគ្រឿងប្រដាប់
ធ្វើពុទ្ធបូជា ។

ព្រះបាទសោភី មួយស្ថិតនៅទី ស្ទឹងនម្មទា
ព្រះអង្គជាន់ទុក លើភកពសុធា ទុកឱ្យមច្ឆា
ក្រួញក្រាបអភិវ័ន្ទ ។

ព្រះត្រៃលោកនាថ ទុកស្នាមព្រះបាទ ៥ឋានសោភ័ណ
តំណាងព្រះអង្គ ឱ្យគង់ប្រាំពាន់ វស្សាគ្រប់គ្រាន់
ទើបស្តេចនិព្វាន ។

# ចតុសង្វេជនីយដ្ឋាន

## បទពាក្យ ៧

គ្រាដែលសម្តេចព្រះពុទ្ធអង្គ ជិតទ្រង់និព្វានឆ្លងត្រៃភព
នោះព្រះអានន្ទបានគោរព ទូលព្រះចមភពដូច្នេះថា ។
បពិត្រសម្តេចព្រះចមត្រៃ សព្វថ្ងៃព្រះអង្គគង់ធរមាន៏
ពួកភិក្ខុសង្ឃផងនានា នៅក្នុងគ្រាមានច្រើនកន្លែង ។
តែដល់រដូវចេញវស្សា តែងតែយាត្រាត្រាច់ស្វះស្វែង
មកគាល់ព្រះអង្គជាគម្លែង គ្រប់ទីកន្លែងទាំងឆ្ងាយជិត ។
ដែលជាឱកាសដ៏បវរ ឱ្យសង្ឃស្មោះសរបានមូលមិត្ត
បានជួបជុំគ្នាយ៉ាងជិតដិត នឹងប្រព្រឹត្តធមិត្រូវគ្នា ។
លុះពេលព្រះអង្គនិព្វាទៅ សង្ឃនៅឯក្រោយនឹងឃ្លាតឃ្លា
មិនបានជួបចូលមូលជុំគ្នា ដូចជាពេលគង់ធរមាន៏នៅ ។
ឯអង្គសម្តេចព្រះមានបុណ្យ ទ្រង់ឮអានន្ទទូលច្នោះកូវ
ក៏ទ្រង់សម្តែងថ្លែងប្រាប់ផ្លូវ ឱ្យបរិស័ទទៅធ្វើទស្សនា ។
ថាក្រោយតថាគតនិព្វាន បរិស័ទអ្នកមានសោមនស្សា
គង់តែមានផ្លូវគួរយាត្រា ទៅធ្វើទស្សនា ៤ កំណត់ ។
មួយគឺឧទ្យានលុម្ពិនី ជាទីប្រសូត្រតថាគត
ពីរគឺដើមពោធិ៍ពិតប្រាកដ ទីតថាគតត្រាស់ដឹងញាណ ។
បីគឺទីឋានល្អក្រៃលែង សំដែងធម្មចក្រជាធម្មយាន
បួនគឺទីចូលព្រះនិព្វាន នៅក្នុងឧទ្យានមល្លៈក្សត្រ ។
ទីសំវេជនីយដ្ឋាន បួននោះនាំបានចិត្តស្ងប់ស្ងាត់

| | |
|---|---|
| ជ្រះថ្លាសង្វេគពន់ពេកក្ដាត់ | ដល់ពុទ្ធបរិស័ទដែលទៅដល់ ។ |
| បើពុទ្ធបរិស័ទទាំងឡាយណា | មិនបានយាត្រាទៅឱ្យស្គាល់ |
| មិនបានទៅថ្វាយបង្គំផ្ទាល់ | ព្រោះក្ដីទញ់ទ័លឬយ៉ាងណា ។ |
| គ្រាន់តែសទ្ធាជ្រះថ្លាពិត | បានបញ្ជូនចិត្តសោមនស្សា |
| ឱ្យទៅគោរពយ៉ាងថ្លៃថ្លា | ពីឆ្ងាយទៅណាយ៉ាងចំៗ ។ |
| ឆ្ពោះសំវេជៈនីយដ្ឋាន | ទាំង ៤ ជាឋានដ៏ឧត្តម |
| នោះអាចកើតផលប្រសើរសម | តាមចិត្តនឹកចំពុទ្ធគុណហោង ។ |

# សាមញ្ញលក្ខណៈ

## បទពាក្យ ៧

| | |
|---|---|
| ព្រះត្រៃលោកនាថជាអម្ចាស់ | ទ្រង់ត្រាស់សំដែងថែងវចនៈ |
| ថាសត្វក្នុងលោកគ្មានឋាវរៈ | មានតែលក្ខណៈ៣ប្រាកដ ។ |
| មួយគឺលក្ខណៈអនិច្ចំ | ពីរគឺទុក្ខំជាកំណត់ |
| បីគឺអនត្តាប្រាកដ | សន្មតឈ្មោះថាត្រៃលក្ខណ៍ ។ |
| លក្ខណៈ ៣ នេះព្រះសាស្ដា | ហៅថាសាមញ្ញៈលក្ខណៈ |
| ជាធម៌ធម្មតាមិនថាវរៈ | មនុស្សសត្វទេវៈចៀសពុំបាន ។ |
| ព្រះធម៌ត្រៃលក្ខណញ្ញាណ | ជាធម្មយានដូចតទៅនេះ |
| អនិច្ចំ គឺថាក្ដីមិនទៀង | កើតហើយតែងល្បៀងមិនគង់នៅ ។ |
| គ្រាំគ្រាទ្រេមទ្រមទ្រុឌទ្រោមទៅ | វិលនៅក្នុងភពគ្រប់រូបា |
| ស្លាប់កើតកើតស្លាប់ជាធម្មតា | ពុំមាននរណាគេចរួចបាន ។ |

ទុក្ខំ គឺថាក្ដីពុំសុខ ជាទុក្ខលំបាកឥតស្រាកស្រាន្ត
ទុក្ខកាយទុក្ខចិត្តច្រើនសណ្ឋាន សព្វសត្វតែងបានរងគ្រប់គ្នា ។
ទុក្ខកាយដោយឈឺពិបាកអត់ នឿយហត់ធ្វើការផងនានា
ទុក្ខចិត្តកើតដោយក្ដីវេទនា អារម្មណ៍ពាធាទាំងក្នុងក្រៅ ។
អនត្តា គឺថាមិនមែនខ្លួន មិនមានមាំមួនមិនឋិតនៅ
ក្នុងក្ដីបញ្ជាសោះសូន្យទៅ បង្គាប់ឱ្យនៅមិននៅឡើយ ។
មិនចង់ឱ្យចាស់ចេះតែចាស់ មិនចង់ឱ្យប្រាសប្រាសព្រាត់ហើយ
មិនចង់ឱ្យឈឺឈឺពុំស្បើយ គ្មានស្ដាប់សោះឡើយទេណាអ្នក ។
អនិច្ចំ ទុក្ខំ អនត្តា ទាំង ៣ នេះណាព្រះទ្រង់ភក្ត្រ
ត្រាស់ហៅថាសាមញ្ញល័ក្ខណ៍ ព្រោះជាក់ជាធមិសត្វធម្មតា ។
តែងជួបប្រទះគ្មានសល់មួយ ឥតជួយគ្នាបានសោះឡើយណា
លុះតែសម្រេចអរហត្តា ចូលមហានិព្វានទើបផុតបាន ។
អ្នកមានស្មារតីនិងប្រាជ្ញា គួរពិចារណាលក្ខណញ្ញាណ
តាមព្រះពុទ្ធអង្គទ្រង់ទូន្មាន ដូច្នេះនឹងបានផលច្រើនហោង ។

## បទពិចារណា បញ្ចក្ខន្ធ

## បទពាក្យ ៧

វាចាលោកិយហៅថាសត្វ វាចាបរមត្ថហៅថាខ្លួន
ថាធាតុឥន្ទ្រិយជៀងជាក់ស្បាន់ ឯខន្ធមាន ៥ ដូចបានស្ដី ។
ទីមួយគឺរូបទាំងតូចធំ ប្រជុំធាតុ ៤ គឺ បឋវី
អាបោ តេជោ វាយោក្ដី ទឹកដីភ្លើងខ្យល់ដោយសង្កាត់ ។

ធាតុ ៤ ប្រជុំជារូបកាយ　　សព្វសត្វទាំងឡាយតាមបរមត្ថ
ជាទីប្រជុំនៃដម្កាត់　　អង្គព្រះភគវ័តហៅរូបក្ខន្ធ ។
ទីពីរគឺវេទនាខាងក្នុង　　ដែលផ្គងអារម្មណ៍តាមថ្នាក់ជាន់
នាំចូលឱ្យចិត្តគតិក្ខួចកាន់　　ជាគ្រឿងកំណាន់ទាំងធីពមុខ ។
គឺទាំងសុខ-ទុក្ខទាំងកណ្តាល　　ត្រអាលចូលជ្រកមកលុយលុក
នាំចិត្តឱ្យសោយនូវសុខទុក្ខ　　មិនសុខមិនទុក្ខឧបេក្ខា ។
ធម្មជាតិគ្រឿងសោយអារម្មណ៍ផង　　បីយ៉ាងនេះហោងក្នុងរូបា
អង្គព្រះលោកនាថជាសាស្តា　　ហៅថាវេទនាខន្ធនោះឯង ។
ទីបីសញ្ញាការចងចាំ　　ចំណាំអារម្មណ៍តាមតំណែង
សខ្មៅខៀវលឿងក្រហមស្លែង　　ខ្លីវែងតូចធំក៏ចាំជាប់ ។
ភ្នែកចាំខាងរូបរាងគ្រប់យ៉ាង　　ត្រចៀកចាំខាងប៉ែកសូរស័ព្ទ
ច្រមុះចាំខាងក្លិនគួរគាប់　　មិនគាប់ក៏ចាំឥតច្រឡំ ។
អណ្តាតចាំខាងរសឱជា　　នានាអាចចាំតាមគ្រឿងផ្សំ
កាយចាំសម្ផស្សច្បាស់ចំៗ　　ចិត្តចាំអារម្មណ៍ផងនានា ។
មនុស្សសត្វតែងក្ខួចកត់ចំណាំ　　ចងចាំអារម្មណ៍តាមទ្វារា
៦នេះឯងព្រះភគវា　　ឱ្យឈ្មោះហៅថាសញ្ញាខន្ធ ។
ទីបួនសង្ខារការចាត់ចែង　　តាក់តែងនូវហេតុទាំង ៣ ជាន់
គឺបាបនិងបុណ្យហើយក្ខួចកាន់　　ទាងឈានសោភ័ណក៏តាក់តែង ។
ខន្ធនេះឈ្មោះថាសង្ខារខន្ធ　　តាក់តែង ៣ ជាន់ដូច្នេះឯង
ទៅតាមគំនិតគិតចាត់ចែង　　ដូចបានសំដែងមកនេះណា ។
ទី ៥ វិញ្ញាណ ៦ ផ្នែក　　ចែកជាចំណែកតាមទ្វារា

ចក្ខុ សោតៈ និងឃានា ជីវ្ហា កាយា មនោរម្មណ៍ ។
ដឹងរូបសម្លេងដឹងក្លិនរស សម្ផស្សដែលប៉ះមកចំៗ
ទ្វារ ៦ នេះព្រះអភិធម្ម ហៅចំឈ្មោះថាវិញ្ញាណខន្ធ ។
ខន្ធ ៥ នេះជាអនិច្ចំ ទុក្ខអនត្តាជៀងជាក់ស្បាន់
តែមនុស្សនិងសត្វតែងគួចកាន់ ឱ្យរូបក្ខន្ធទៀងគ្រប់គ្នា ។
តែរូបមិនស្ថិតស្ថេរទៀងទាត់ មិនសុខប្រាកដដូចប្រាថ្នា
មនាតែនិព្វានទើបសុខា ឥតជាតិជរាមរណៈឡើយ ។

**បទពិចារណា បញ្ចក្ខន្ធ!**

## សិរីឱន

## បទព្រហ្មគីតិ

សិរិឱនលំទោនកាយ ហត្ថាថ្វាយបង្គំផ្ទង់
ចិត្តស្មោះចំពោះត្រង់ អង្គព្រះមុនិន្ទពិនលោកា ។
កាលទ្រង់គង់នៅឡើយ ព្រះគុណអើយតែងមេត្តា
ប្រោសសត្វមនុស្សទេវតា រាល់វេលាពុំដែលខាន ។
ឥឡូវព្រះពុទ្ធអង្គ នឹងទ្រាំគង់យូរពុំបាន
យាងចូលកាន់និព្វាន ខានទូន្មានយើងរាល់គ្នា ។
សាវ័កព្រះជាម្ចាស់ គង់ច្រើនណាស់នៅត្រៀបត្រា
បាត់តែអង្គសាស្ដា ពីគ្រានោះលុះឥឡូវ ។
រឿងនេះសែនវិវេក គួរសង្វេគពេកណាស់កូវ
ព្រះរូបគង់ច្រម៉ូវ សត្វត្រូវពឹងយកនិស្ស័យ ។

ពេញបូណ៌មីវិសាខា ថ្ងៃនេះណាព្រះម្ចាស់ថ្លៃ
ប្រសូត្រចេញចាកផ្ទៃ និងក្សត្រថ្លៃចេញបព្វជ្ជា ។
បានត្រាស់ពោធិញាណ ចូលនិព្វានឋានសោភា
ពេញបូណ៌មីវិសាខា មានចរិតបួននោះឯង ។
កាលស្ដេចនិព្វានទៅ សាវ័កនៅគិតកោតក្រែង
រៀបធ្វើគ្រឿងតាក់តែង រាល់វេលាតែរៀងរាប ។
មកដល់ឥឡូវនេះ យើងខ្ញុំនេះវន្ទាក្រាប
នឹកដល់ព្រះទ្រង់ភាព ជាបិញ្ញលាភទាន់សាសនា ។
ខ្ញុំបានគោរពហើយ ព្រះគុណអើយខ្ញុំប្រាថ្នា
ទាន់ព្រះមេតេយ្យា ត្រាស់ឯក្រោយដោយប្រពៃ ។
ពាក្យប៉ងបំណងណាត់ កុំបីភ្លាត់ឡើយម្ចាស់ថ្លៃ
សូមទាន់ព្រះមេត្តេយ្យ គ្រាន់អាស្រ័យទៅនិព្វាន ។

**ចប់ បទសិរីជិន!**

## សត្តមហាឋាន

### បទបឋ្យាវត្ត

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិសុរកំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនាឃរំ ។
បញ្ចមំ អជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សត្តាហំ មុនិ សេចិតំ ។
ឯតេ សត្ត មហាឋានា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។

### កាព្យបឋ្យាវត្ត

ទី១បល្ល័ង្កដែលព្រះសាស្តា ចំម្រើនអានាបានស្សតិ
ទី២ព្ស៊សានពីដើមពោធិ ហៅថាអនិមិស្សកចេតិយ ។
ទី៣គឺទីដែលព្រះជិនស្រី ព្រះអង្គឃ្មាតខ្មីទ្រង់យាងចង្ក្រម
ទី៤គឺទីដែលព្រះបរម ចំរើនអភិធម្មជាធមិបរមត្ថ ។
ទី៥គឺទីដែលព្រះភគវ័ត ទ្រង់គង់ស្ងប់ស្ងាត់ក្រោមអជ្ជបាល
ទី៦ទីវិសេសវិសាល សម្រិតសម្រាលក្បែរស្រះមុច្ចលិន្ទ ។
ទី៧គឺទីព្រះមុនិន្ទ សង្រួមកាយិន្ទ្រិយ៍រាជាយតនា
ទីទាំង៧ដែលពោលនេះណា ជាទីថ្លៃថ្លាមានពិតប្រាកដ ។
ក្នុងជម្ពូទ្វីបនេះជាកំណត់ ប្រាជ្ញលោកសន្មតិហៅថាឋានធំ
ព្រោះជាកន្លែងដ៏ល្អឧត្តម ជាទីមនោរម្យដល់មនុស្សទេវតា ។
ជាទីសម្រាប់អ្នកមានសទ្ធា នាំគ្នាវន្ទាយកបុណ្យកុសល
ខ្ញុំសូមក្រាបថ្វាយបង្គំឆ្ពោះដល់ ឋានធំនិមិលនោះពីចំងាយ ។

---

## អដ្ឋមហាឋាន

### បទបឋ្យាវត្ត

**បឋមំ សុម្ពីនីជាតំ　　　ទុតិយំ ពោធិមុត្តមំ**
**តតិយំ ធម្មចក្កញ្ច　　　ចតុត្ថំ បាលិលេយ្យកំ ។**
**បញ្ចមំ ច នាឡាគិរី　　　ឆដ្ឋមំ បាដិហារិយំ**
**សត្តមំ ទីរិទេវិញ្ច　　　អដ្ឋមំ បរិនិព្វុតំ ។**
**ឯតេ អដ្ឋ មហាឋានា　　　ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ　　　អហំ វន្ទាមិ ទូរតោ ។**

**កាព្យបឋ្យាវត្ត** (កុំច្រឡំហៅកាព្យនេះថាពាក្យ៨)

ឋានធំទាំងឡាយ៨កន្លែង　　　ជាទីស្ងប់ស្ងែងដល់ពពួកសត្វ
ទី១ឧទ្យានជាឋានព្រៃស្ងាត់　　　គឺព្រៃសាលវ័តនីដែលទ្រង់ប្រសូត្រ ។
ទី២ប្រសើរដែលព្រះទ្រង់ស្រូត　　　ត្រាស់ក្រោមដើមពោធិព្រឹក្សឧត្តម
ទី៣កន្លែងដែលព្រះបរម　　　សំដែងព្រះធម្មឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុ៥អង្គគឺពួកបញ្ចវគ្គ-　　　គីយ៏ដែលជាអ្នកបំរើព្រះអង្គ
ដោយព្រះទ័យថ្លៃងមិនអាចលះបង់　　　ហើយយាងតម្រង់ពីដើមជ្រៃទៅ ។
ទី៤គឺទីដែលទ្រង់គង់នៅ　　　ក្នុងឋានព្រៃជ្រៅឈ្មោះបាលិលេយ្យ
ទីនោះគ្មានមនុស្សមានតែសត្វព្រៃ　　　គឺដំរីថ្លៃបម្រើព្រះអង្គ ។
ទីគឺទីដែលព្រះពុទ្ធអង្គ　　　ផ្ចាញ់សត្វទ្រនងនាឡាគិរី
ទីនោះមានមនុស្សបែកពួកជាទ្វី　　　ទៅមើលពិធីនៃព្រះសម្ពុទ្ធ ។
ទី៦កាលព្រះសព្វញ្ញុត-　　　ញ្ញាណជាមកុដត្រៃលោកាចារ្យ
ផ្ចាញ់និគ្រន្ថដោយបាដិហារ្យ　　　ឈ្មោះល្បីអស្ចារ្យគ្មាននរណាដល់ ។

ទី៧កាលព្រះទសពល | គង់លើមណ្ឌលថ្មព្រះឥន្ទ្រា
ទ្រង់បានសំដែងនូវព្រះធម្មា | ប្រាកដនាមថាធមិអភិធម្ម ។
សងគុណមាតាដែលមានគុណធំ | លើព្រះបរមសម្ពុទ្ធថ្លៃថ្លា
ទី៨កាលព្រះសាស្តា | ផ្ទំក្រោមដើមសាលព្រឹក្សទាំងគូ ។
ពេលនោះឯងហើយព្រះសព្វញ្ញូ | ព្រះអង្គជាគ្រូយាងចូលនិព្វាន
ឋានធំ៨កន្លែងនេះមាន | ប្រតិស្ឋានជម្ពូទ្វីបា ។
ជាទីដែលពួកមនុស្សនិងទេវតា | មានចិត្តជ្រះថ្លាគួរទៅយង់យល់
ខ្ញុំសូមឱនកាយបង្គំឆ្ពោះដល់ | ឋានធំនិមល៨នោះឯង
សូមសុខចំម្រើនកើតយូរអង្វែង | ទុក្ខទោសចំបែងកុំកើតមានឡើយ ។

**ចប់ ឋានធំ!**

រសទាំងពួងមានរនៃខន្ធជាដើមក្តី រសនៃសុធាភោជនរបស់ទេវតាយ៉ាងឧក្រិដ្ឋក្តី ជាបច្ច័យនាំឱ្យលិចលង់ទៅ ត្រដាបត្រដួសក្នុងសង្សារវដ្តហើយសោយនូវសេចក្តីទុក្ខច្រើន ចំណែករសនៃធមិពោលគឺ ពោធិបក្ខិយធមិ ៣៧ ក្តី លោកុត្តរទាំង ៩ ក្តី ប្រសើរជាង ដូចនេះបានជាព្រះអង្គសំដែងថាធម្មរស ឈ្នះអស់រសទាំងពួង ។

សូមជូនពរទាំងឡាយ ៥ ប្រការគឺៈ អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ ចូរចំរើនក្នុងព្រះពុទ្ធសាសនា កុំបីក្លាយទៅជាបការៈដទៃឡើយ ។

**ចប់ គំណាព្យ !!!**

**********

**ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា**
Bodhikaram Temple, 1197 Deer Park Road, Ottawa, ON, Canada, K2E 6H5
www.bodhikaram.com